# ៧

ប៉ឹង ! ប៉ឹង ! ប៉ឹង ! សូរជួងអ្នកចាំទ្វារវិទ្យាល័យ ប្រកាសប្រាប់អ្នកផងថាម៉ោង ៩ និង ១៥ នាទីយប់ហើយ ។ អនុរក្សទះដៃផ្ទួងៗ លាន់រំពង ដើម្បីឲ្យពពួកយុវជនដឹងច្បាស់ថា ជាពេលត្រូវទំលាក់មុងដេករៀងៗខ្លួន ។ សព្ទអ៊ូអរអំបាញ់មិញក៏រម្ងាប់ស្ងាត់ស្ងៀមម្តងបន្តិច ។ នៅសល់តែសំឡេងខ្សឹបខ្សាវ ។ ឬសូរខ្យល់ផាត់ស្លឹកឈើ និងមាត់មៀមយំម្តងៗ ។ គេពន្លត់អគ្គិសនីទាំងអស់ទុកតែដួងមួយដែលព្យួរបន្តោងនៅក្បែរដំណេកនៃអនុរក្ស ។

ប៊ុន-ធឿន ដែលមានគ្រែនៅចុងម្ខាងនៃល្វែងនោះ បានក្រោកឡើងស្រវារកទៀននិងឈើគូសមកអុជ ហើយរើហោប៉ៅអាវដែលព្យួរលើក្បាលដំណេក យករូបថតដែលនាងវិធាវីបានឲ្យមក កាលដែលជួបគ្នានៅក្រោមដើមស្វាយមកសំឡឹងមើល ។ មួយសន្ទុះ ទើបទាញសំបុត្រមួយច្បាប់ដែលសរសេរនៅលើក្រដាសពីរសន្លឹក ពេញទៅដោយអក្សរល្អិតៗ ។ អក្ខរានេះមានសេចក្តីថា :

ក្រុងបាត់ដំបង, ថ្ងៃ ៥ ៦ ២ ព.ស.២៤៧៦

## ជូនជំនឿដល់គូជីវិត

ខ្ញុំមានចិត្តមមៃគិតមកបងមិនមានដាច់មួយវេលាឡើយ ។

- ខ្ញុំដែលនៅឯនាយ តែងនឹកថា ពេលថ្មើរនេះសមបងចូលរៀន
- ពេលថ្មើរនោះសមបងនិយាយកំសាន្ត និងពួកម៉ាក ព្រោះទុក្ខចំបែង ចេះតែងំក្នុងដើមទ្រូង មិនដឹងទៅនិយាយប្រាប់នរណាឡើយ ។ ពីដើមខ្ញុំមានរំពឹងច្រើនទៅលើសៀវភៅ ដែលអាចបន្ថែមបន្លំកង្វល់បានខ្លះ ។ ឥឡូវនេះ ចេះតែស្មុបសៅ អានសៀវភៅក៏មិនបានល្ហែក្នុងចិត្តដែរ ។

ដូច្នេះ ខ្ញុំខំបន់ស្រន់ អស់ទាំងទេវតាឲ្យលោកជួយជ្រោមជ្រែង ឲ្យបងរៀនសូត្របានប្រកបដូចសេចក្តីប្រាថ្នា ដោយខ្ញុំសព្វថ្ងៃនៅមានរំពឹងតែលើបងមួយប៉ុណ្ណោះ ។



បង ! ខ្ញុំដឹងចិត្តបងថា មានសេចក្តីស្នេហាដល់អូនជាទីបំផុត ។ ហេតុនេះខ្ញុំសូមកុំឲ្យបងមានការតក់ស្លុតនឹងដំណឹងដែលពណ៌នាខាងក្រោមនេះឲ្យសោះ ឲ្យបងខំប្រុងស្មារតីតែខាងរៀនសូត្រទៅចុះ ។ ជនដទៃ មានចេះភ្លេចពាក្យសន្យា ចំណែកខ្ញុំមិនដូច្នោះទេ ខ្ញុំមានតែពាក្យមួយប៉ុណ្ណោះមិនចេះប្រែប្រួលឡើយ ។

បង ជាច្រើនថ្ងៃមកហើយ ខ្ញុំបានសង្កេតឃើញកិរិយាម្តាយ ខ្ញុំប្លែកពីសព្វមួយដង ។ ទឹកមុខគាត់ចេះតែញញឹមញញែម ហើយថែមទាំងមានវាចាមកកាន់ខ្ញុំថា :

កូនឯងនេះចំជាមានវាសនាហើយ ! ។ គាត់និយាយតែប៉ុណ្ណោះ ខ្ញុំដេញដោលសួរគាត់យ៉ាងណា គាត់នៅតែស្ងៀមធ្វើព្រងើយ ។

ឯយាយដៃវិញ ដូចបងជ្រាបស្រាប់ហើយ គាត់មានសេចក្តីស្រឡាញ់បងឯង និងខ្ញុំដូចជាបុត្រចេញពីផ្ទៃគាត់ មិនដឹងជាហេតុម្តេចឡើយ បានជាមុខគាត់ចេះតែស្រពោនមិនសប្បាយ ។

កិរិយានិងទឹកមុខខុសពីគ្នា នៃជនទាំងពីរនាក់ដែលមានចិត្តស្រឡាញ់ខ្ញុំដូចគ្នានេះ នាំឲ្យខ្ញុំគិតអើយសែនគិត ! ខ្វល់អើយសែនខ្វល់ !

ស្រាប់តែម្សិលមិញនេះ ឱបងអើយ ! ខ្ញុំទើបនឹងភ្ញាក់ខ្លួន ។

បងគង់ស្គាល់ថៅកែ ណៃស៊ាន ដែលជាអ្នកមានធំមួយ នៅក្នុងបាត់ដំបង ។ ប្រពន្ធណៃស៊ាន នេះឈ្មោះថូ ។

អ្នកទាំងពីរនេះ គេមានកូនកំលោះមួយ ឈ្មោះ ណៃស៊ិត ។ មនុស្សកំលោះនេះហើយ ដែលម៉ែដៃបានប្រាប់ខ្ញុំថា ជាអ្នកដែលដេញតាមមើលខ្ញុំ ហើយធ្វើឫកងងុលជ្រឹមមកលើខ្ញុំ នៅឱកាសដែលខ្ញុំទៅមើលបុណ្យ ព្រះសពលោកគ្រូចៅអធិការវត្តដំរីស ជាមួយនឹងបងប្អូនជិតខាង ។ ឱសែនក្នាញ់ពេក !

ពីម្សិលមិញនេះ មីងថូគេបរឡានមកបញ្ឈរនៅមុខផ្ទះ ហើយមានចាស់ទុំ ជាច្រើននាក់លើកផ្លែឈើ ចំណី ចំណុក សំពត់ ព្រែ ផាមួង ហូល ចរបាប់ និងខៀនបីក្រឡី ដង្ហែគ្នាឡើងមកលើផ្ទះ ។

វត្ថុទាំងនោះជាជំនូនយកមកភ្ជាប់ពាក្យដណ្ដឹងខ្ញុំ ។ តាមដែលម៉ែផៃគាត់ប្រាប់ខ្ញុំនោះ ម៉ែខ្ញុំនិងខាងប្រុសបានដាច់ស្រេច ថាផ្សំផ្គុំខ្ញុំឲ្យទៅចៅណៃស៊ត នៅខែពិសាខមុខនេះហើយ ។

ឱម៉ែអើយ ! ម្ដេចឃើញតែទ្រព្យសម្បត្តិ ម្ដេចមិនមើលលក្ខណៈមនុស្ស ម្ដេចក៏មិនស្មើចិត្តកូនផង ? បើបានទុក្ខ ឬសុខយ៉ាងណា ក៏នៅលើរូបកូនទាំងអស់ទេតើ !

ណ្ហើយបង ខំរៀនសូត្រចុះ កុំឲ្យព្រួយរន្ធត់អ្វី ។

ទោះបីយ៉ាងណាក៏ដោយ មុខជាចៅណៃស៊ត មិនបានជួបប្រសព្វនឹងអូនទេក្នុងជាតិនេះ ។

នៅទីបំផុតនេះ ខ្ញុំសូមឲ្យបងទទួលសេចក្ដីរលឹកយ៉ាងធ្ងន់របស់ខ្ញុំ ។

វិធាវី

សំបុត្រនេះប៊ុនធឿនបានអានជាច្រើនចប់ តែដូចជានៅមិនស្កប់ស្កល់សោះ ។ កំលោះនេះនឹកស្រណោះនាងវិធាវីពន់ប្រមាណ ។ ដេកសញ្ជឹងមួយសន្ទុះ ក៏ក្រោកយកដងប៉ាកកាដែលមានទឹកខ្មៅចេញឯង មកទ្រាលសរសេរសំបុត្រតបមានសេចក្ដីខាងក្រោមនេះ :

ក្រុងភ្នំពេញ ថ្ងៃ ១៥ យ៉ាំងវិយេរ ១៩៣៣

## តបដំណឹងដល់អូន

អូន សេចក្ដីស្រឡាញ់របស់បង បណ្ដាលឲ្យបង មិនចង់ឲ្យអូន នាងមានសេចក្ដីព្រួយ ដោយសារបងសោះឡើយ ។ បងធ្លាក់ក្រហើយ ។ លុះបងចេញធ្វើការទៅក៏មិនសង្ឃឹមបានប្រាក់ខែប៉ុន្មានដែរ ។ ហេតុនេះ នាងកុំមានប្រខូសរ៉ាយ ខទឹងចិត្តម្ដាយនាង



ដូច្នោះឲ្យសោះ គាត់ជាមនុស្សចាស់ បើគិតធ្វើការអ្វីនីមួយៗ សឹងតែមើលដំណើរការនោះបានផ្លូវវែងឆ្ងាយ ។ ចូរនាងព្រមទទួលយកគូស្រករ ដែលគាត់ទុកដាក់ឲ្យ កុំប្រកែកឡើយ ។

ណៃស៊ត ដល់គេចាស់ដៃ ចាស់ជើងទៅ មុខជាបានជាពាណិជ្ជមួយ យ៉ាងធំនៅប្រទេសកម្ពុជា ។ ចំណេះគេក៏មាន សម្បត្តិគេក៏មាន ដែលជាលក្ខណៈមួយ អាចនាំឲ្យអូនបានសុខសំរាន្តទៅថ្ងៃក្រោយ ។

កុំអូនប្រកាន់ខឹងនឹងកិរិយាមិនគប្បីនៃកំលោះនេះ ។ ខុសម្ដង ឆ្គងម្ដង គួរបំភ្លេចចោលទៅ ។

ចំណែកបងវិញ បងនៅជាប់ស្រឡាញ់អូនពេញដូចពីដើម ។ តែសុំឲ្យនាងទុកបងដូចជាបងបង្កើតទៅចុះបងក៏ទទួលព្រមដែរ ។

សរសេរចប់ហើយ ប៊ុន-ធឿន ក៏ប៉ត់សំបុត្រច្រកស្រោមមួយ ។ នៅលើស្រោមនោះមានចារសេចក្ដី "សូមឲ្យនាងសោភ័ណជាប្អូនលៃលកជូនសំបុត្រនេះ ឲ្យនាងវិធាវី ឲ្យបានផ្ទាល់ដៃ " ។

ទៀនដែលប៊ុន-ធឿន អុជបំភ្លឺ នៅសល់ឆេះពព្រឹមៗ ។ លុះដល់គល់ហើយ ក៏រលត់ឯងទៅ ។ ប៊ុន-ធឿនទាញភួយមកលាតដណ្ដប់ ហើយដកដង្ហើមធំដែលជាសំឡេងនៃជម្ងឺអួលផ្សាក្នុងទ្រូងតែម្នាក់ឯង កណ្ដាលចំណោមនៃពួកម៉ាកដែលដេកលក់ជាសុខសាន្ត ។

## ៨

ព្រះសុរិយារះទន្ទេងចាំងចុងដូងលៃ ដែលមានវាយោមកបន្ទន់យោលយាលទៅមក ។ អ្នកផងទាំងឡាយដើរហួរហែចុះឡើងពាសពេញ ។ យាយនួននិងម៉ែផៃស្ពៀកពាក់ស្អាតបាត នាំនាងវិធារីដែលមានសាច់ស្លាំង ហើយដណ្តប់ក្រមា ដើរលុយទឹកឆ្លងស្ទឹងទៅផ្សារ ។

ស្ទឹងសង្កែ នៅរដូវប្រាំង តែងរីងស្រកស្ទើរអស់នៅសល់តែខ្សែទឹកតូចៗតាមប្រឡោះកូនកោះខ្សាច់ដុះឡើងក្នុងផ្ទៃនៃផ្លូវទឹក ។ ដោយសារក្រុងបាត់ដំបងមិនសូវសំបូណ៌ដោយស្ពាន និងដោយសារទឹករាក់ពេករកប្រើទូកដមិនកើតមហាជន តែងនាំគ្នាលាត់សំពត់លុយឆ្លងកាត់ទៅ ពីត្រើយម្ខាងទៅត្រើយម្ខាង ។

គ្រានោះ មានឈ្នួលម្នាក់លីវ៉ាលីសស្បែកមួយធំនៅលើស្មាឆ្វេង និងយួរកូនវ៉ាលីសតូចមួយនៅដៃស្តាំដើរតាម ក្រោយស្ត្រីទាំងបីប្រាណ ។

នាងវិធារីខំប្រឹងទប់ខ្លួនកុំឲ្យដួល ដោយកំឡាំងទឹកហូរច្រាន ។ ដំណើរនាងក៏ធេងធោងទ្រេតទ្រោតមិនដូចជាជន ដែលលុយទឹកជាមួយនាងហើយដែលមានអាយុច្រើនជាងនាងនោះឡើយ ។ មុខស្លេកស្លាំងនិងដំណើរបែបនេះ ជាហេតុចង្អុលឲ្យឃើញថា នាងមានសុខភាពមិនមាំទាំទេ ។

កាលបើបានដល់ផ្សារវិលហើយ យាយនួនគាត់តំរង់ទៅចំណតឡានទៅសៀមរាប ។ លុះបានតថ្លៃរួចគាត់ក៏បង្គាប់ ឲ្យកូនគាត់និងម៉ែផៃឡើងជិះលើរថយន្តនោះ ។ លុះគាត់ប្រាប់ឲ្យគូលីឡានម្នាក់ លើកវ៉ាលីសទាំងពីររៀបដាក់ទៅលើដំបូលរថយន្តអោយបានស្រួលបួលឲ្យគាត់រួច ទើបគាត់ដើរទៅរកទិញម្ហូបចំណីយកទៅទុកអាស្រ័យតាមផ្លូវ ។

គាត់ទិញនំប៉ុងបានពីរ ហើយខំជ្រៀកញែកបំណងទៅទិញ សាច់ក្រកចំហុយទៀត  ស្រាប់តែឮមាត់គេស្រែកសួរ ។



- យីថៃតើហ្ន៎ ! អញ្ជើញទៅណាមកណា បានជាទិញអីវ៉ាន់យ៉ាងនេះ ?

យាយនួនគាត់ងើបមើលឡើងឃើញនាងថូ គាត់ក៏ញញឹមឆ្លើយ :

- ចា៎ះនាង , ខ្ញុំជូនកូនខ្ញុំទៅសៀមរាប ។

- បើយ៉ាងនេះ ចាំឲ្យគេបើកឡានតូចខ្ញុំជូនទៅ ! កុំជិះឡានឈ្នួលធ្វើអី វាពិបាកណាស់ ។

- អរណាស់ហើយនាង ខ្ញុំទិញកន្លែងស្រេចទៅហើយកុំឲ្យនាងព្រួយ ។

- មានកើតអីថៃ ឡានខ្ញុំទំនេរសោះ ប៉ុនជាទៅលេងជាមួយគ្នាទេតើ ។

ចិត្តយាយនួនចង់ទទួលអាការគួរសម នៃជន្លងគាត់ពន់ពេក តែគាត់នឹកខ្លាចទាស់ចិត្តកូនគាត់ ។ គាត់ក៏នៅស្ងៀមមិនតប ហើយលូកដៃទៅរើសសាច់ក្រកឲ្យថិនថ្លឹងចំនួនកន្លះនាឡិ ។ ឯនាងថូទៅឈរចាំមើល ។ លុះឃើញយាយនួនទិញរួចហើយ ក៏ចៅរៅសួរថែមទៀត :

ឯណា ក្មួយ ថែ ?

វ៉ានៅចាំឡានឯនោះ ។

- បើអីចឹង ខ្ញុំចង់ទៅជួបមួយភ្លែត ។

ថាហើយ ស្ត្រីទាំងពីរនាក់ក៏នាំគ្នាដើរត្រង់ទៅឡានឈ្នួល :

យី ក្មួយឯងទៅលេងសៀមរាបហ្នឹង ?

នាងវិធារី ដែលភ្លេករវល់សំឡឹងភ្លឹកទៅឆ្ងាយ លុះឮសំដីនេះហើយក៏ភ្ញាក់ខ្លួនព្រើត ។ នាងងាកមុខ មកឃើញនាងថូ ភក្ត្រនាងដែលពីមុនស្លាំងសដូចទេសឯក ក៏ប្រែជាក្រហមទុំភ្លាម ដោយសេចក្តីក្តៅក្រហាយ ។ តាំងតែពីនាងដឹងខ្លួនថា ម្តាយនាងលើកឲ្យទៅជាកូនប្រសានាងថូ កាលណាមកនាងចេះតែទោម្នេញដំណេកមិនបាន បាយទឹកអ៊ីក៏ឡើងជាប្រហាត ឥតឱជារស ។ នាងដែលមិនហ៊ាន នឹកខឹងនឹងមាតាក៏បង្វិលសេចក្តីក្រោធនេះដាក់ទៅលើគ្រួសារដែល ប្រាថ្នាចង់បាននាងជាកូនប្រសាវិញ ។ យាយនួន

ឃើញកូនគាត់ចេះតែមុខស្រពោន ហើយស្គមថយកម្លាំងទៅៗ ដូច្នោះក៏គិតឃើញថា គួរនាំកូនគាត់ទៅលេង រំហើយចិត្ត ដោយយល់ថា ការទស្សនាបុរាណដ្ឋានទាំងពួង ដែលឋិតនៅក្នុងខេត្តសៀមរាប និងអាចនាំឲ្យកូនគាត់រីករាយសប្បាយ មានសាច់មានឈាមឡើង និងអាលរៀបការឲ្យទាន់ខែពិសាខខាងមុខ ។

នាងវិធារីដែលឈ្វេងយល់គំនិត កំបាំងម្ដាយខ្លួនដូច្នោះ ក៏រឹតតែគ្នាន់ក្នាញ់តែមិនចេញស្ដីថាអ្វីឡើយ ។ លុះឮសំដីនាងថូមកប្រលោមសួរទៀត សេចក្ដីក្រោធពិរោធទាំងប៉ុន្មាន ក៏ដាលពុះពោរឡើងពេញទាំងទ្រូង តែដោយនាងជា អ្នកមានពូជពង្ស នាងក៏ខំទប់សង្កត់ហើយឆ្លើយតបដោយសំឡេងនៅញ័របន្តិច ។

- ចាំះមីង ម៉ែគាត់នាំខ្ញុំទៅលេងអង្គរ ។
- យីក្មួយ ! ឯងកើតអីហ្នឹង ក៏ស្គមម្ល៉េះ ? មកកុំជិះឡាននេះ ចាំជិះឡានមីងវិញ មីងប្រើឲ្យទៅយកមួយរំពេចបានហើយ ។
- អរគុណណាស់ហើយមីង កុំឲ្យមីងមានព្រួយឡើយ ម្យ៉ាងទៀតខ្លួនខ្ញុំនេះមិនមានរោគ អ្វីទេ ។

នាងថូរៀបនិងហាមាត់ឆ្លើយទៅហើយ ប៉ុន្តែជួនជាពេលនោះ មានមនោគតិមួយចំឡែក ហើរមកប៉ះសតិគាត់ គាត់ក៏ឈប់នៅស្ងៀមទៅវិញ ។ មួយសន្ទុះក្រោយមក នាងថូក៏លាអ្នកដំណើរទាំងនោះ ក៏ដើរចេញទៅ ។

ឡានរត់លឿន ...រត់លឿនកាត់វាលស្រែដែលមានជញ្ជ្រាំងជាប់នៅជី នាងវិធារីដែលមានម្ដាយនាងនិងម៉ែដៃអង្គុយអមសងខាងនាង ខំគយគន់រុក្ខជាតិ ជួរភ្នំនិងទេសភាពទាំងពួង ដែលកំដៅព្រះអាទិត្យរដូវប្រាំង កំទេចជាផង់ធូលីមើលយូរទៅនាងរោយភ្នែក នាងក៏ដាក់មុខសញ្ជឹងសញ្ជប់ ខ្យល់ល្បឿនរត់បក់បោកសក់នាងយោលរវិចៗ ។

ឱគូសង្សារថ្លើមប្រមាត់ កម្មអ្វីមកកាត់ឲ្យព្រាត់ខ្លាយ
ពីថ្ងៃនេះទៅបែកចេញឆ្ងាយ ឱស្ដាយសែនស្ដាយ ស្ដាយខ្លួនក្មេង



ម៉ែអើយមានសីលនៅពេញខ្លួន ម្ដេចអោយកូនខ្លួនសោកសង្រេង
ម្ដេចហ៊ានផ្ដាច់កូនពីគូព្រេង វង្វេងនេះព្រោះតែក្ដីលោភ

ពាក្យកាព្យដែលនាងបានអានឃើញក្នុងសៀវភៅមួយ ក៏នៅថតជាប់ក្នុងសតិនាង ។ លុះនាងត្រូវរងទុក្ខប្រកបគ្នានឹងលក្ខណៈនៃពាក្យនេះ ទំនុកឃ្លោងក៏រោយជ្រុះចេញមកដោយឯងៗ ។

តាំងតែពីនាងដឹងខ្លួនថា ម្ដាយលើកនាងឲ្យទៅចៅណៃស៊ិតកាលណាមក ទឹកមុខនាង ក៏ចេះតែក្រៀមក្រំអាប់រស្មី ។ បុប្ផាទាំងពួងដែលរីកស្គុះស្គាយជាលំអធម្មជាតិ បើត្រូវកំដៅព្រះអាទិត្យ ឬមានម្លប់អ្វីមកគ្របដណ្ដប់ តែងនឹងស្រពោន រុះរោយចោលគ្របករាយនៅលើពសុធា យ៉ាងណាមិញ នារីដែលមានរូបឆោមលោម ពណ៌ដែលជាលំអនៃមនុស្សធម៌ តែកាលណាមានអាការអកុសលមកបៀតបៀន ក៏សឹងតែធ្លាក់ទៅក្នុងសភាវៈចង្រៃនោះ ដូចគ្នាដែរ ។

នាងវិធារី គិតដល់ពាក្យដែលបានសន្យា គិតដល់សេចក្ដីស្នេហារបស់នាង គិតដល់រឿងរ៉ាវសៀវភៅប្រលោមលោក ដែលនាងបានអានខ្លះក្នុងអក្សរសាស្ត្រសៀមគិតដល់ ប៊ុន-ធឿន ដែលនាងធ្លាប់ដឹងចិត្តដឹងថ្លើម គិតមមៃសព្វគ្រប់ទៅ នាងសល់សែនចំបែងក្នុងចិត្ត នាងយល់ម្ដងថា ត្រូវជំរាបម្ដាយនាង ពីការណ៍មិនចូលចិត្ត នឹងនាងថូព្រោះថាស្ត្រីនេះ ជាអ្នកវាយកំពស់ដោយអាងសម្បត្តិ និងពីដំណើរស្អប់ឈ្មោះណៃស៊ិតដែលជាកំលោះព្រហើនស្រវឹងដោយធនធាន មិនមានចិត្តមេត្តាករុណាដល់អ្នកតូចទាបឡើយ ។ នាងគិតពន្យល់ម្ដាយនាងថា ឈ្មោះណៃស៊ិតចង់បាននាងជាភរិយានេះ ដោយប្រាថ្នាត្រេកនឹងលំអរូបនាងប៉ុណ្ណោះ ។ តែបើកាលណា នៅភពប្រសព្វគ្នាយូរទៅនាងនឹងមានកូនចៅ ឯរូបរាងក៏អន់ទ្រុឌទ្រោមទៅដែរ ឈ្មោះនេះក៏នឹងលះបង់ចោលនាងហើយ នាងនឹងលុះនៅក្នុងសេចក្ដីតោកយ៉ាកពុំខាន ។ តាមពាក្យអ្នកផងគេនិយាយថាឈ្មោះ ណៃស៊ិតមានចំណូលនឹងបរទាកម្មណាស់ ហើយថែមទាំងបានធ្វើនារីម្នាក់ឲ្យមានគភ៌ រួចហើយឈ្មោះណៃស៊ិតក៏បង់ប្រាក់កាស បន្តិចបន្តួចចោលស្ត្រីនោះមានទំនួល

ដូចគេបរិភោគគុយទាវឬកាហ្វេ ហើយចេញប្រាក់ឲ្យទៅអ្នកលក់យ៉ាងនោះឯង ។ នឹកហើយនាងខ្សឹកខ្សួល តែនឹងហាមាត់ជំរាបម្ដាយតាមយោបល់នេះមិនរួចដោយនាងជាយុវតីមួយស្រគត់ស្រគំ ធ្លាប់ពន្លយកិរិយាមារយាទតាមលំអាននៃទំនៀមបុរាណចាស់ទុំជានិច្ច ។ នាងមានសេចក្ដីអៀនខ្មាសច្រើន មិនហ៊ានចរចាពីសេចក្ដីស្នេហាសោះឡើយប្រការមួយទៀត នាងគិតឃើញថា សម័យនេះហួសឱកាសទៅហើយ ទោះនាងប្រកែករឹងរូសដូចម្ដេច ក៏មុខតែយាយនួនគាត់ប្រែសំដីថាទេវិញ មិនបានឡើយ ។ ខែពិសាខ ! នៅតែមួយខែទៀតទេ ... នឹកឃើញថា ពេលអាពាហ៍ពិពាហ៍កិច្ចនៅខ្លីដូច្នោះនាងក៏ព្រឺព្រួច ហើយសុំបួងសួងទេវតាឲ្យជួយយោងសេចក្ដីស្នេហានាងឲ្យផុតពីគ្រោះធំនេះ ។

ឡានបរទៅមុខ ! ទៅមុខ ! ...នេះប្រជុំជនមង្គលបុរី ... នេះសេរីសោភ័ណ ! អ្នកដំណើរក៏នាំគ្នាចុះស្រទៅប្រញិបប្រញាប់ទិញបាយចិនអាស្រ័យ ។ យាយនួនគាត់ក៏ស្រាយកញ្ចប់ ហើយកាច់នំប៉័ងមួយកំណាត់និង បេះសាច់ក្រកមួយគូឲ្យទៅម៉ែផៃ ទើបគាត់ហៅកូនគាត់ :

- មកអាវី ស៊ីនំប៉័ងទៅ ។

នាងវិធាវី ក៏យកនំប៉័ងប៉ុនមេដៃបិទនឹងសាច់ក្រកមួយចំណិត ។ ម្ហូបនេះហាក់ដូចជាមានឱជារសល្វីងចត់ផ្ដេសផ្ដាសក្នុងមាត់នាង ។ នាងលេបមិនរួច ក៏ខ្ជាក់ចោលទៅនឹងថ្នល់ ។ ក្នុងវេលានោះមានឆ្កែខ្មៅមួយដែលមាន អង្កែស៊ីពេញខ្លួន ដើរមករើសកញ្ជាក់នាងវិធាវី ឆក់បរិភោគហើយសំដែងទឹកមុខឲ្យឃើញថា ចំណីនោះឆ្ងាញ់ពីសាយ៉ាងចំឡែក ។ នាងក៏កាច់នំប៉័ងមួយដុំប៉ុនកដៃបោះឲ្យទៅសុនខនេះទៀត ។ សត្វនេះមុននឹងត្របាក់ចំណីនោះ ក៏លើកភ្នែកសំឡឹងមកនាង មានកិរិយាហាក់ដូចជាចង់ថ្លែងសេចក្ដីអរគុណ ចំពោះនាង ! នាងវិធាវីក៏កើតសញ្ជឹង : ឱសត្វតិរច្ឆាននេះ ចេះនឹកគុណ ឯមនុស្សម្ដេចក៏ភ្លេចសេចក្ដីសន្យាហ្ន៎ ?

- អាវី ម៉េចក៏មិនញ៉ាំនំឲ្យច្រើនទៅ នៅជាងពាក់កណ្ដាលផ្លូវទៀតទើបដល់សៀមរាប ។ ញ៉ាំទៅ តិចទៅជាខ្យល់ ជាព្យុះអីទៀតហើយ ។



- ចាំះ ម៉ែ , ខ្ញុំមិនសូវឃ្លានទេ ។

យាយនួនគាត់ក៏ងើបមើលភក្ត្រកូនគាត់ ហើយងាកចេញភ្លាមបែរសំឡឹងទៅទីឆ្ងាយមានទឹកមុខព្រួយចំប្រប់ ទ្រូងគាត់តឹង ខ្លួនគាត់ស្រយង់ ។ គាត់គិតឃើញថា កិរិយាចំឡែកនៃកូនគាត់យ៉ាងនេះ ដល់មានគូគ្រងទៅមុខជានឹងផ្លាស់ប្ដូរវិញពុំខាន ... គំនិតនេះ ធ្វើឲ្យយាយនួនធូរទ្រូង ព្រោះនៅជិតថ្ងៃខែណាស់ហើយ ។

# ៩

សៀមរាបជាកូនក្រុងមួយ ស្អាតញញឹម លំអដោយថ្នល់ដែលមានរុក្ខជាតិចោលម្លប់ទៅលើត្រឈឹងត្រឈៃ និងដោយកូនស្ទឹងតូចមួយ ដែលមានទឹកថ្លាហូងហូរមកបង្វិលរហាត់ធ្វើឲ្យឮសំឡេងថ្ងូរយ៉ាងស្រងេះស្រងោច ។ អ្នកដំណើរណាក៏តែងប្រតិព័ទ្ធស្រឡាញ់ទី ប្រជុំជននេះ ។

នៅសាយណ្ហកាល រថយន្តបើកចូលក្នុងក្រុងសៀមរាប ហើយទៅឈប់ចតនៅត្រង់ផ្សារវិល ។ អ្នកដំណើរទាំងពួងក៏ប្រញាប់ប្រញាប់ចុះពីលើឡាន, ម្នីម្នារកអីវ៉ាន់រៀងខ្លួន ។ យាយនួនគាត់ឈរនៅចិញ្ចើមថ្នល់ ហើយរំពៃរកមើលឆ្វេងស្តាំ ។ ខណៈនោះមានបុរសម្នាក់ ជាកណ្តាលមនុស្សពាក់អាវទេសឯកស ស្លៀកខោឡាញ់ខ្មៅ ដើរចូលមកជិតគាត់ហើយលើកដៃសំពះ :

- ខ្ញុំជំរាបសួរថៃ ។

យាយនួនគាត់ដាក់ភ្នែកមកចំ :

- ឱ ! បេងជុនទេនេះ ឯងខំសំឡឹងរកមើល ...
- ថៃ ! ឯណាអីវ៉ាន់ថៃខ្លះ ? ខ្ញុំនឹងអាលឲ្យគេជញ្ជូនដាក់រ៉ឺម៉កទៅ
- បេងជុនអើយ ខ្ញុំគ្មានអីទេព្រោះបន្ទាន់ណាស់ , រកស្អីៗ គ្រាន់ជាបញ្ញើក៏មិនបានផង ។
- ចាំធ្វើធ្វើអីថៃនុ៎ះ តែអញ្ជើញមកលេងខ្ញុំ ក៏អរណាស់ទៅហើយ ។
- បើអាវី ឯងសំពះសួរមា ។ កញ្ញានេះឮហើយក៏លើកដៃសំពះ ជំរាបសួរទៅលោកបេងជុន ។

លុះអ្នកធាក់រ៉ឺម៉ក បានជញ្ជូនវ៉ាលីសទាំងពីរដាក់ស្រេចបាច់ហើយយាយនួន នាងវិធាវីព្រមទាំងម៉ែដៃនាំគ្នាឡើងជិះក្នុងយាន ។ ឯឈ្មោះបេងជុន ក៏ឡើងជិះប៊ីស៊ីក្លែតអមរ៉ឺម៉ក ហើយនិយាយសួរសុខទុក្ខតាមធម្មតាទៅ ។



ឈ្មោះបេងជុននេះជាអ្នកមានធនធានមួយ គ្រាន់បើនៅក្នុងខេត្តសៀមរាប ។ គាត់ធ្លាប់នៅធ្វើជំនួញស្រូវឯបាត់ដំបង ហើយតែងមានពឹងពាក់គ្នាទៅមក និងខ្មោចឪពុកនាងវិធាវី ។ ឯមេត្រីភាព ក៏កើតឡើងរវាងគ្រួសារទាំងពីរនាំឲ្យរាប់អានគ្នាទៅវិញទៅមកយ៉ាងស្និទ្ធ ។

ហេតុដែលបណ្តាលអោយយាយនួន គាត់ដាច់ស្រេចនាំកូនគាត់មកកំសាន្តអង្គរនេះ ពីព្រោះតែគិតឃើញដល់បេងជុនប៉ុណ្ណោះឯង ។ មុនពេលដែលគាត់ចេញដំណើរមួយថ្ងៃនោះ គាត់បានពឹងអ្នកជិតខាងម្នាក់ឲ្យវាយខ្សែលួសមកប្រាប់ឈ្មោះបេងជុន ដើម្បីកំណត់ពីថ្ងៃនឹងពេលដែលគាត់ចេញពីបាត់ដំបងមកសៀមរាប ។

ផ្ទះបេងជុនសង់នៅត្រើយខាងឆ្វេង ដែលមានដើមចំប៉ាធំៗដុះបាំងពីមុខ ។ ក្នុងរបងដែលធ្វើអំពីឥដ្ឋនៅប្រប់ថ្នល់នោះ មានចោះជាក្លោងទ្វារធំមួយ វិចិត្រទៅដោយផ្កាកុលាបដែលរីកស្រស់បំព្រង ។ នៅប្រប់ផ្ទះធំ រថយន្តជិះលេងមួយជ្រកក្នុងរោងដែលមានជញ្ជាំងថ្ម ដំបូលប្រក់ក្បឿង ។ នៅមាត់កំពង់ចំមុខលានផ្ទះ កង់រហាត់មួយវិលគ្មានស្រាកស្រាន ហើយចាក់ទឹកពីបំពង់ទៅក្នុងទីមួយ ដែលសំរាប់បង្ហូរទៅស្រោចរុក្ខជាតិក្នុងភូមិឋាន ។

នាងវិធាវី កាលបើដល់គេហដ្ឋាននេះហើយ ក៏ហាក់ដូចជាមានអាកាសត្រជាក់មករុំស្រោបកាយនាង ព្រោះផ្ទះនេះស្រឡះល្វឹងល្វើយ ហើយមានតុ ទូ ធ្វើសុទ្ធពីបេងចាស់មានរបៀបសមឥតមានទាស់ភ្នែក នៅលើក្តារ កំរាលធ្វើពីក្រកោះរលីងថ្លាដូចកញ្ចក់ ។

នាងសុចិត្រា ភរិយានៃបេងជុន ជាស្ត្រីមួយមានអាយុជាងសាមសិបឆ្នាំហើយ តែដោយនាងមិនដែលមានបុត្រនោះ រូបនាងក៏នៅស្រស់ចំប្រប់ដូចព្រហ្មចារីសុទ្ធវិស័យ ។ កាលបើឃើញអ្នកដំណើរទៅដល់ហើយ នាងក៏ស្ទុះមកទទួលដោយសាទរ ហើយនាំងនាងវិធាវី និងយាយនួនទៅបង្ហាញបន្ទប់ដែលបំរុងទុកជូន ដើម្បីឲ្យយាយផៃគាត់យកអីវ៉ាន់ទៅទុកដាក់ ។ រួចហើយ នាងសុចិត្រា ក៏អញ្ជើញអ្នកដំណើរទាំងពីរទៅងូតទឹកក្នុងបន្ទប់ជំរះកាយ ។

ទិកត្រជាក់ដែលហូរស្រប់រាងកាយនាងវិធារី បានធ្វើឲ្យនាងមានកំលាំងព្រមទាំងយកសេចក្ដីរំហើយ ក្នុងចិត្តមករំលុបមន្ទិលសៅហ្មងបានជាច្រើនភាគផង ។ដូច្នេះហើយ នាងក៏ទទួលដោយញញឹមញញែម សេចក្ដីអញ្ជើញនៃស្ត្រីម្ចាស់ផ្ទះ ឲ្យទៅដើរលេងក្នុងសួនច្បារ ។ នាងសុចិត្រា កាលបើបានគយគន់ រូបរាងនិងកិរិយាស្រគត់ស្រគំនៃនាងវិធារីហើយ ក៏មានចិន្តាចាប់ស្រឡាញ់ ហាក់ដូចជាប្អូនរួមផ្ទៃតែមួយ ។ នារីទាំងពីរនេះត្រាច់កំសាន្តតាមប្រឡោះគុម្ពផ្កា ហើយសំដីដែលនិយាយរកគ្នារទូៗ អណ្ដែតរសាត់ទៅច្រឡូកច្រឡំ និងសត្វនៃភូមរីដែលហើរត្រិបសុគន្ធមាលា ។ នាងចរចា...ចរចា ដើរតាមផ្លូវខ្សាច់ដែលមានស្មៅបៃតងនិងផ្កាគ្រប់ពណ៌អមសងខាង ។ នារីនាងលីលា...លីលាទឹកមុខ ញញឹមប៉ប្រែកណ្ដាលទេសភាពមួយល្អ ឥតខ្ចោះ ។ ជួនប្រទះនឹងជើងម៉ាវែង ដែលជ្រកក្រោមម្លប់ចំប៉ាមួយធំ ស្ត្រីទាំងពីរក៏នាំគ្នាអង្គុយព្រលឹងអណ្ដែតអណ្ដូងទៅឆ្ងាយ ឯនេត្រាគយគន់មើលរហាត់ទឹកដែលវិលញើបៗ ហើយថ្ងូរពំនោលមិនចេះខ្ជិលឡើយ ។ វិញ្ញាណនាងវិធារី ក៏ភ្លឹកស្លុងទៅក្នុងសកលមួយថ្មី ឯសេចក្ដីអួលក្ដៅទាំងប៉ុន្មាន ក៏ផាត់ប្រានបានឆ្ងាយមួយគ្រាដែរ ។

ប៉ុន្តែដោយហេតុតែសេចក្ដីសុខសំរាន្តនៃមនុស្សលោក មិនដែលឋិតថេរនៅយូរបាន សំឡេងបេងជុនដែលនិយាយថា ថៃ ខ្ញុំស្ដាយណាស់ កុំតែឡានខ្ញុំវាខូច កុំអីបើកជូនថៃមើលប្រាសាទលេងសប្បាយ ដូច្នេះក៏មកកាត់ចិញ្ចាំការភ្លាំងភ្លេចស្មារតី នៃនារីនោះអស់ទៅ ។ នាងវិធារីដោះពីយល់សប្តិទាំងភ្នែកបើកនេះហើយ ក៏សំឡឹងមើលទៅឃើញ យាយនួននិងបុរសម្ចាស់ផ្ទះដើរត្រង់មក ។

យាយនួនគាត់តបទៅបេងជុនវិញ :

មិនអីទេ ជួលតែរទេះសេះមួយ បានហើយ

- មិនស្រួលសោះ ថៃ ! ណ្ហើយស្អែកនេះ ថៃអញ្ជើញរទេះសេះមើលវង់តូចសិនចុះ ។ ចំណែកខ្ញុំ ខ្ញុំនឹងនៅខំធ្វើឡានឲ្យរួចទាន់ខានស្អែកនេះ ដើម្បីជូនថៃមើលខាងវង់ធំ មើលបន្ទាយស្រី ហើយប្រសិនជាមានពេលយើងទៅដល់ភ្នំគូលែនម្ដង ។



នៅក្នុងព្រៃដែលដុះព័ទ្ធបុរាណប្រាសាទនានា មានរបស់ពីរយ៉ាងដែលនាំបង្អើតដួងចិត្តទេសចរ ឲ្យរីងរឹតតែស្រងេះស្រងោចខ្លោចផ្សា ដោយសេចក្ដីស្ដាយអាល័យដល់កេរ្ដិ៍ស្នាដៃនៃបុព្វបុរសខ្មែរ ។ វត្ថុនោះហាក់ដូចជាខ្យល់ព្រលឹង និងសំឡេងនៃប្រវត្តិមាតុភូមិយើង ។

ពេលរសៀល ! វេលាដែលព្រះសុរិយាកំពុងដុតចំហុយអស់ទាំងធម្មជាតិវៃកណ្ដឹងយំទំលាក់សំឡេងពីចុងស្រឡៅ ឬចុងឈើទាលដែលខ្ពស់ត្រដែតក្នុងអាកាស ។ សព្ទតូរ្យតន្ត្រីចំឡែកនេះ ជ្រាបចូលសព្វសព៌ាង្គកាយ ហើយមករុំស្រោបបេះដូង នាំឲ្យអ្នកដំណើរទាំងពួងយន់ចិត្តអាសូរដល់ស្រុកកំណើតដែលធ្លាប់ថ្កុំថ្កើង ។

នៅខែចេត្រនិងពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរផ្ការំដួលបញ្ចេញរំភើយពិដោរក្រអូបឈ្ងុយ ។ បើជួនជាមានវាយោបក់បន្តិចៗ ផង អ្នកដែលដើរយកអាកាសពេលល្ងាចតាមថ្នល់នេះ នឹងមានចិត្តរសាប់រសាយអណ្ដែតអណ្ដូងប្រហែលជានឹងលាន់មាត់ថា ទោះជាឋានតុសិត ក៏មិនសប្បាយជាជាងនេះមើលទៅ ។

ឱក្លិនរំដួល ! ឱសំឡេងវៃ ! កំឡាំងអ្នកដូចជាទិព្វឱសថដែលអាចចូលមករំសាយសេចក្ដីសោកសង្រេងមួយពេលបាន ។

ធៅពេលរសៀល រទេះសេះមួយបរចូលតាមក្លោងទ្វារខាងកើតមកក្នុងកំពែងនគរធំ ។ ត្រចៀកប្រុងស្ដាប់ភ្នែកប្រុងមើល នាងវិធារីអង្គុយអែបនឹងមាតាដែលនិយាយចេកចាច នឹងនាងសុចិត្រាគ្មានឈប់មាត់ឡើយ ។ នាងស្រីក្រមុំ គិតក្នុងចិត្តថា : " ឱពីបុរាណកាល ម្លឹះសមមានមនុស្សអ៊ូអរកុះកុម ម្ដេចឡើយឥឡូវ ក៏វិលទៅជាព្រៃស្ងាត់អស់រលីង មុខគួរស្រណោះពេក" ។ នៅក្នុងពេលដែលចិត្តនាងកំពុងតែលន្លោចទៅក្នុងអតីតសម័យនៃមាតុភូមិដូច្នោះ ស្រាប់តែរទេះសេះឈប់ង៉ក់ ហើយឮនាងសុចិត្រានិយាយមកកាន់នាងថា "មកក្មួយ យើងចុះមើលប្រាសាទបាយ័នសិន " ។ នាងវិធារីរៀបខ្លួននឹងចុះ ទទួលងាកមុខមើលទៅម្ខាងថ្នល់ ឃើញអង្គពុទ្ធបដិមាមួយយ៉ាងធំបិទមាស ប្រាលផ្អោគង់នៅក្នុងរោងប្រក់ក្បឿងមួយ ។ ឃើញដូច្នោះហើយ នាងថ្លែងថា ទេមីងខ្ញុំចង់ថ្វាយបង្គំព្រះអង្គនេះសិន សឹមយើងទៅមើលប្រាសាទជាក្រោយ ។

សេចក្ដីប្រាថ្នានេះ អ្នកសហាចរបានយល់ព្រមផងហើយនារីនាង ក៏ទាញយកទៀន ១ធូបបីសរសៃពីសំណុំ ហើយក៏លីលាទៅកាន់សំណាក់ព្រះពុទ្ធរូបអង្គនោះ ។ លំដាប់ក្រោយដែលបានអុជគ្រឿងសក្ការបូជារួច នាងក៏តាំងសូត្រនមស្ការយ៉ាងផ្ចិតផ្ចង់ ។ លុះចប់ហើយនាងក៏តាំងនឹកប្រាថ្នាសុំតែក្នុងចិត្តថា ឱព្រះអង្គដែលធ្លាប់ស្រោចស្រង់សត្វលង់ទឹកបាន សូមព្រះអង្គទ្រង់ សន្ដោសខ្ញុំព្រះករុណាឲ្យបាន ផុតរណ្ដៅពីគ្រោះធំ ។ ខ្ញុំព្រះករុណាតាំងពីឃើញរស្មីព្រះអាទិត្យមកដល់សព្វថ្ងៃនេះ ខ្ញុំព្រះករុណា ឥតបានធ្វើបាបជនណា សត្វណាមួយឡើយ ។ខ្ញុំព្រះករុណាបានកាន់សីលប្រាំខ្ជាប់មិនរសាយ បានធ្វើបុណ្យបំពេញទានតាមកំឡាំងទ្រព្យនៃយុវជន ហើយបានស្គាល់ព្រះធម៌ទាំងពួងផង ។ ហេតុនេះសូមព្រះអង្គសន្ដោសជួយខ្ញុំព្រះករុណាឲ្យបានរួចពីក្រញាំ ចៅណៃស៊ិតកំណាចចេញ ហើយឲ្យខ្ញុំព្រះករុណាជួបតែបងប៊ុន-ធឿនដែលជាគូព្រេងកំសត់វៀងទៅ ... ។ នាងវិធាវីកំពុងតែផ្ចិតផ្ចង់បន់យ៉ាងនេះ ស្រាប់តែមានរថយន្តមួយ បើកមកឈប់ប្របរទេះសេះ ។ នាងដាក់ភ្នែក មើលទៅឃើញនាង ថូ និងចៅណៃស៊ិតដើរមកចំរោង នាងក៏លើកនេត្រាសំឡឹង ទៅចំព្រះភក្ត្រព្រះពុទ្ធរូប ដែលនៅតែញញឹមស្ងួតដូចពីមុន ។ ទឹកភ្នែកក៏ហូរ មកស្រប់មុខនាង ។ នាងនឹកក្នុងចិត្តថា : "ឱព្រះអង្គអើយ ! មារជ្រែកមកដល់ទៀតហើយ " ។

ឯយាយនួនដែលអង្គុយរង់ចាំពីក្រោយខ្នងកូនគាត់នោះ កាលបើបានឃើញជន្លងគាត់មកដល់ ក៏ស្ទុះទៅសាកសួរសុខទុក្ខដោយរាក់ទាក់ ។ ក្រោយដែលបានលើកដៃសំពះសួរគ្នាទៅវិញទៅមក ជាមួយនាងសុចិត្រារួចហើយនាងថូ ក៏និយាយទៅកាន់យាយនួន :

- ថៃអើយថៃ កាលដែលខ្ញុំប្រទះថៃនៅផ្សារស្វាយប៉ោ រួចខ្ញុំត្រឡប់ទៅផ្ទះវិញនោះ ខ្ញុំបានប្រាប់ណៃស៊ិតថា ថៃអញ្ជើញទៅលេងអង្គរ នុ៎ះណៃស៊ិត ក៏ចេះតែកន្ទក់កន្ទេញឲ្យខ្ញុំនាំវាមក ដើម្បីយកឡានមកជូនថៃដើរលេង ។



យាយនួនគាត់ឮសំដីនេះហើយ គាត់ក៏ងាកទៅមើលមុខចៅណៃស៊ិត ហើយទឹកមុខគាត់ក៏រីកថ្លា ដោយសេចក្ដីប្រតិព័ទ្ធយ៉ាងជ្រាលជ្រៅ ។ ឯចៅណៃស៊ិតដែលឈរដាច់ពីខាងក្រោយស្ត្រីទាំងពីរនោះ មានរវល់តែនឹងបែរបៀងនាយអាយ ញញឹមរំពៃទៅរកនាងវិធាវី ធ្វើឲ្យយុវតីនេះក្ដៅរំខានពន់ប្រមាណ ។ នាងខំទប់មិនឈ្នះ ក៏បបួលម្ដាយនាងឲ្យឡើងជិះរទេះសេះត្រឡប់ទៅសៀមរាបវិញ ។ នាងថូឮដូច្នោះហើយ ក៏ខំនិយាយអង្វរលួងលោមនាងវិធាវីឲ្យជិះឡានជាមួយខ្លួន ។ បុត្រីយាយនួនដែលភ្លើងទោសៈកំពុងផុតរោលដើមទ្រូងនោះ ក៏ខំសង្កត់ចិត្តឆ្លើយដោយស្រួលវិញ :

- ខ្ញុំសូមអរគុណមីងចុះ តែខ្ញុំឥឡូវជិះឡានមិនបានទេ ព្រោះបើជិះកាលណាហើយ ខ្ញុំចេះតែវិលមុខ ។

ថាហើយនាងក៏ទាញដៃនាងសុចិត្រាឡើងរទេះសេះ ។ ឯយាយនួនដែលស្មារតីនៅតែនឹងឡាននាងថូ ក៏ធ្វើមុខជូរហើយដើរតាមកូនគាត់ទៅដោយទាល់គំនិត ... ។

កាលដែលយាន នៃស្ត្រីទាំងបីនាក់ចរបានបន្តិចទៅមេឃខែចេត្រដែលថ្លាត្រចះជាច្រើនថ្ងៃមកហើយ ក៏ប្រែជាងងឹតមានពពកខ្មៅតាន់តាប់មកបាំងពន្លឺព្រះអាទិត្យភ្លាមព្រមទាំងមានព្យុះបក់ធូលីនិងស្លឹកឈើហុយដង្គោលផង ។ ហើយមិនយូរប៉ុន្មាន ក៏មានភ្លៀងបង្អុរធ្លាក់មកដោយគ្រាប់ធំៗ ជះសាចទឹកស្ត្រីដំណើរទាំងបីរងាញ័រខ្លួនចំប្រប់ ។ ទទួលពេលនោះ រទេះបរដល់ភូមិមុខនាគ ដែលនៅត្រង់មុខប្រាសាទអង្គរវត្ត នាងសុចិត្រានិងយាយនួន ក៏បបួលនាងវិធាវីឲ្យជ្រកភ្លៀងនៅទីនោះសិន ។ ប៉ុន្តែយុវតីនេះដែលនឹកក្នាញ់មមៃក្នុងចិត្តចង់ឲ្យបានដល់ទីលំនៅឆាប់ៗ ព្រោះនឹកក្រែងចៅណៃស៊ិតមកទាន់ទៀត ក៏និយាយអង្វរឲ្យរទេះខំស្រូតតំរង់ទៅសៀមរាបតែម្ដង ។

នៅពេលល្ងាចនោះ នាងវិធាវីកើតក្ដៅរោលក្នុងខ្លួន ហើយបណ្ដាលឲ្យនាងទៅជាគ្រុននិទ្រាដណ្ដប់ផ្ដួយ ឥតបានទទួលម្ហូបអាហារអ្វីឡើយ ។

## ១០

មានយប់មួយនៅវេលាអធ្រាត្រ នាងវិធារីដែលនិទ្រាមិនលក់សោះនោះ ក៏ក្រោកឡើងបើកបង្អួចក្បាលដំណេក ។ ខ្យល់ត្រជាក់បោកបក់ក្លិនរុក្ខជាតិ ស្ទុះចូលមកអង្អែលភក្ត្រានាង ។ នៅខាងក្រៅ លោកខែបញ្ចាំងរស្មីទន់ត្រជាក់ដូចព្រៃមកគ្របលើសាកលទ្វីប ។ នៅក្នុងមេឃពណ៌ខៀវថ្លាត្រយង់ ដុំពពកសៗ ដូចកប្បាសរសាត់បន្តគ្នា ជួនកាលមកបាំងវង់ព្រះចន្ទបណ្តាលឲ្យស្រទំស្អាប់មួយភ្លែត ។ កាលណាពពកនោះអណ្តែតផុតទៅ ពន្លឺរាជនីនៃរាត្រីមកចាំងលើធាងដូងដែលយោលរេរាដោយវាយោ ហើយដែលភ្លឺភ្លែតៗ ដូចជាបន្ទះដែកស្និត ។

នៅក្នុងសន្ធិយាស្ងាត់នេះ នាងវិធារីនៅកណ្តែងកណ្តោចឈឺអួលផ្សាតែម្នាក់ឯង ។ ចិត្តនាងនឹកទៅប៊ុន-ធឿន មិនលោះវេលា ។ ឱម្ល៉េះនៅពេលមួយនេះ សមអ្នកបងនិទ្រាសុខសំរាន្ត ឬមួយក៏មានចិត្តគិតមកនាងខ្លះដែរក៏មិនដឹង ។ នៅពេលដែលនាងគិតឃើញដូច្នេះ ទឹកភ្នែកពីរដំណក់ហូររមៀលចុះមក ។ នាងនឹកដល់ពពួកទេវតាដែលមានតេជាអានុភាពម្តេចក៏ទុកនាងឲ្យ រងកម្មអ្វីដល់ម្ល៉េះ ? ម្តេចក៏មិនរំលាយជីវិតនាងនៅគ្រាដែលទៅមើលប្រាសាទអង្គរទៅ ?... អង្គរ ? នាងនឹកឡើងសែនគ្នាន់ក្នាញ់ក្តៅរោល ដូចឃើញនៅនឹងមុខថ្មី ៗ ។ យីអាណៃសិតនេះ ចំជាព្រហើន ថ្លើមធំមែនហើយហ្ន៎ ! វាហ៊ានទៅរលុករលុយឯងកំពុងថ្វាយបង្គំព្រះអង្គ ។ នាងនឹក ឃើញវេលាដែលឡើងជិះរទេះមកទាំងភ្លៀង នាងនឹកឃើញកាល ដែលនាងដេកញ័រកន្ត្រាក់ទទូរជួយពីរ បីជាន់ដោយនាងចាប់គ្រុនយ៉ាងធ្ងន់ ។ នាងនឹកឃើញ ដល់នាងសុចិត្រាដែលជួយបីបាច់ថែរក្សានាងក្នុងពេលនោះ ។ នាងនឹកដល់ថៅកែបេងជុន ដែលរត់រកពេទ្យទាំងរាត្រី ដើម្បីយកថ្នាំមកចាក់ឲ្យនាង... លុះតែនាងបានគ្រាន់ស្រយាល ។ ឱបើប្រសិនណាជានាងមានសំណាងទៅថ្ងៃក្រោយ នាងនឹងមិនភ្លេចគុណជនទាំងពីរនាក់នេះឡើយ ។

លុះឃើញថា នាងបានគ្រាន់ស្រួលបួលបន្តិចហើយ ម្តាយនាងក៏បាននាំនាងវិលមកផ្ទះសំបែងវិញដោយរួសរាន់ ។ ចំណែកយាយនួនដែល មានព្រួយដោយ ខ្លាចក្រែង



ទាស់អធ្យាស្រ័យនៃនាងថូព្រោះយល់ឃើញថា កូនគាត់មានកិរិយា មិនគប្បីក្នុងកំពែងអង្គរធំនោះ គាត់ក៏បានទៅនិយាយសុំចិត្តកុំឲ្យនាងថូគេចាប់ថ្នាក់ប្រកាន់អ្វីសោះឡើយ ។ ស្ត្រីនោះឮហើយក៏សើចកាច់កក្អាកក្អាយ ហើយថា ចែកុំព្រួយអីយ៉ាងនោះក្មេងនៅព្រហ្មចារីតែងអៀនខ្មាសគួ ស្រករយ៉ាងនេះឯង ។ យាយនួនគាត់បានធូរដើមទ្រូងពីរឿងនេះ ហើយក៏ពាំសំដីនេះដោយមានទឹកមុខរីករាយ មកប្រាប់កូនគាត់ភ្លាម ។

នាងវិធារីដែលអង្គុយក្នុងយប់ស្ងាត់ កាលបើនឹកឃើញកិរិយាយ៉ាងនេះនៃម្តាយនាងហើយ នាងក៏សែនក្នាញ់តូចចិត្ត ដោយនឹកខ្មាសគេពន់ប្រមាណ ។ នាងមានចំបែងជាអនេក ។ បានពេលណា នាងរៀបតែរបូតមាត់ជំរាបម្តាយពីហេតុដែលនាងស្អប់ឈ្មោះ ណៃសិត តែសេចក្តីអៀននិងដំណើរទាស់ខុសប្រពៃណីមកសង្កត់អណ្តាតនាងឲ្យស្ងៀមទៅវិញ ព្រោះយល់ឃើញថា តាំងពីបុរាណនាយមក ស្ត្រីខ្មែរមិនមានអំណាចរើសប្តីលើខ្លួនឯងទេ ។ បើឪពុកម្តាយទុកដាក់ល្អអាក្រក់ដូចម្តេច ក៏ត្រូវតែទទួលយកជានិច្ច ។ ទំលាប់យ៉ាងនេះ នាងយល់ឃើញថា ជាការមិនប្រកបនឹងយុត្តិធម៌សោះ ។ ព្រះឥន្ទ្រ ព្រះព្រហ្ម ដែលមានឫទ្ធានុភាពក្រៃលែង ម្តេចឡើយក៏មិនមកជួយបំបែរចិត្តម្តាយខ្ញុំផង ! ឱកុសលនៃបុណ្យទាំងឡាយដែលខ្ញុំបានសាងមក ម្តេចក៏មិនមកជួយខ្ញុំឲ្យផុតពីទុក្ខទម្ងន់នេះចេញ ? ឱបងប៊ុន -ធឿនសំឡាញ់អើយ ! ទ្រូងអូនគ្មានធូរស្បើយវេលាណាទេ ។ បើនៅតែចុកណែនអួលផ្សាយ៉ាងនេះទៅ ឃើញថានឹងធន់ធារមិនបានយូរប៉ុន្មានឡើយ ។

នាងវិធារីនៅត្រាំក្នុងទុក្ខសង្រេងយ៉ាងនេះ ទាល់តែឮមាត់ក្អែក ដែលប្រស្រ័យនៅដោយចុងអម្ពិល តាមជួរមាត់កំពង់ ស្រែកខ្វកឡើងទ្រហឹងអឹងអាប់ ។ នាងងាកទៅខាងកើតក៏ឃើញពន្លឺព្រាងៗ របស់ព្រះសុរិយាដែលរះបំភ្លឺលោក ។ នាងក្រោកឡើងមានដៃជើងរួយស្រពន់ ហើយដើរទៅបើកមុងចូលដំណេក ។

នាងវិធារី កើតទុក្ខឥតដំណេកអង្គុយយ៉ាងនេះសព្វទិវារាត្រី ។ ខ្លួននាងល្ហិតល្ហៃស្គមនៅតែស្បែកដណ្តប់ឆ្អឹង ។ យាយនួនឃើញដូច្នោះហើយ ក៏បង្ខំឲ្យខាងប្រុសគេរៀបចំឲ្យបានក្នុងពេលឆាប់ ដើម្បីឲ្យបុត្រីគាត់បានស្វាមីហើយនឹងអាលឲ្យនាំគ្នាដើរលេង

កំសាន្តរំហែចិត្ត ។ ដូច្នោះហើយនាងថូ ដែលសមចិត្ត និងគំនិតយ៉ាងនេះផង ក៏ប្រើគួលីមកជំរះស្មៅយកទីកន្លែងទុកធ្វើរោងផ្កាស្លា រោងចុងភៅ ហើយជញ្ជូនដើមស្លានៅទាំងមូលខ្លះ ពុះជារនាបខ្លះ ព្រមទាំងស្បូវកណ្តបដែលយកបង្គរទុកបំរុងជាស្រេច ។

នាងវិធាវី កាលបើឃើញវត្ថុទាំងនោះហើយ ក៏រឹតតែស្មុបសៅខ្លាំងឡើងៗ ។ នាងលែងចេញវាចាស្តីថាអ្វីសោះ បើគេដេញដោលសួរពីសុខពលនាងច្រើនពេក នាងក៏ញញឹមដោយស្រពោន ហើយបែរមុខចេញទៅ ។

ប្រហែលពីរបីថ្ងៃមក ចាប់មានភ្នាក់សួត មកអង្រួនដើមទ្រូងឲ្យនាងឈឺផ្សាអស់ប្រាណ ។ នៅព្រហាមយប់មួយដែលឥតបាននិទ្រាសោះ ស្រាប់តែនាងក្អកយុះមកមានផ្លាក់លោហិតស្រស់ៗ គេយកកន្តោរមកត្រងឈាមនោះបានចំនួនពីរពែង ។ ឯនាងអស់កំលាំងពេក ក៏ដួលស្រប៉ូបនៅត្រង់កន្លែងអង្គុយ ។

យាយនួននិងយាយផៃ ភ័យស្រឡាំងកាំង ក៏នាំគ្នាលើកគ្រាហ៍នាងវិធាវី ទៅដាក់លើគ្រែ ហើយម៉ែផៃរត់ទៅពឹង អ្នកជិតខាងម្នាក់ឲ្យគេអាណិត ទៅអញ្ជើញគ្រូពេទ្យមកជាប្រញាប់ ។

នៅពេលដែលគ្រូពេទ្យមកដល់ នាងវិធាវីនៅតែស្តូកស្តឹងមិនទាន់ដឹងខ្លួននៅឡើយ ។ គ្រូពេទ្យចូលទៅចាប់ដៃ ឆ្វេងអ្នកឈឺមកពិនិត្យជីពចរ ហើយយល់ថាស្ត្រីក្រមុំនេះមាន កម្លាំងខ្សោយពេកណាស់ ។ ដូច្នេះហើយ គេបើកប្រអប់យកថ្នាំមួយបំពង់មកចាក់ឲ្យ ទើបគេនិយាយសុំឲ្យអ្នកឈឺទៅសំរាកកម្លាំងកុំអោយមានផលរមាស់ ឬ មានអ្នកណាធ្វើអោយឃ្នើសចិត្ត អ្វីឡើយ ។

លុះគ្រូពេទ្យចុះទៅបានមួយស្របក់ នាងវិធាវីក៏ភ្ញាក់ដឹងខ្លួនឡើង ។ យាយនួនគាត់អររខិបរខុប លើកបបរនិងត្រីងៀតដែលបំរុងទុកមកឲ្យនាង អាស្រ័យ ។ យុវតីនេះ ឮម្តាយលួងលោមឲ្យញុំាពេក ក៏កើតមានចិត្តអាណិត ហើយខំត្រដរមកអង្គុយជិតម្តាយ ទើបលើកស្លាបព្រាចុកអាហារ ។ នាងទើបតែនឹងលេបបានពីរ បីមាត់ប៉ុណ្ណោះស្រាប់តែមានរថយន្តមួយបើកមកឈប់នៅមុខផ្ទះ ហើយគេឃើញនាងថូចុះប្រញិបប្រញាប់ មកស្រែកពីចម្ងាយ ។



- ចៃអើយ ចៃ ខ្ញុំទើបឮគេនិយាយអំបាញ់មិញនេះសោះ ។

នាងវិធាវី ឮសូរមាត់នោះក៏ងាកមើលទៅ ស្គាល់ជានាងថូក៏នឹកអួលក្តាញ់ភ្លាម ។ សម្បុរមុខនាងឡើងក្រហមច្រាលដោយសេចក្តីខឹង ឯរោគក្អកក៏ងើបឡើងទាញអង្រួនខ្លួននាង ។ លុះនាងស្តោះទៅក្នុងកន្តោរ គេឃើញធ្លាក់សុទ្ធតែឈាមក្រហមឆ្អៅ ។

ឃើញដូច្នោះហើយ នាងថូក៏ស្ទុះទៅត្រកងនាងវិធាវី :

- យីក្មួយអញឈឺអីដល់យ៉ាងនេះហ្ន៎? ចៃបានអញ្ជើញគ្រូណាមើលហើយ ឬនៅ?

យាយនួនដែលភ័យស្ទើរគ្មានស្មារតីនោះ ក៏ហាមាត់ឆ្លើយឡើងទាំងប៉ប៉ិបប៉ប៉ុប ។

- គ្រូពេទ្យបារាំងគេទើបនឹងចុះទៅមុន នាងអញ្ជើញមកដល់បន្តិចនេះ ។

- ឱចៃកុំរកពេទ្យ ! ពេទ្យគេមើលមិនពូកែដូចគ្រូខ្មែរទេ ។ ខ្ញុំស្គាល់លោកសង្ឃមួយអង្គដែលតែងចង្ក្រមភាវនា នៅក្នុងគុហាភ្នំសំពៅ ។ លោកចេះមន្តវិជ្ជាពូកែណាស់ ។ លោកធ្វើទឹកមន្តឲ្យភ្លូត បើបានងូតទឹកម្តងនឹងឃើញស្បើយ បីដងនឹងជាស្រឡះ ។

- យីលោកនៅឆ្ងាយអីម្ល៉េះ តើបាននរណាគេទៅនិមន្តលោកមក ?

- ចៃព្រួយអី ឡានខ្ញុំឈឹបទៅឈឹបមក ពីនេះទៅភ្នំសំពៅ ឆ្ងាយប៉ុន្មាន !

យាយនួនក៏ស្រែកហៅម៉ែផៃឲ្យដកហូត ពីខ្លាក់យកទៀនមួយគូនិងធូបមួយសំណុំមកជូននាងថូ ។ ស្ត្រីនេះក៏ម៉ឹម្មា ចុះទៅថា ដើម្បីនឹងចាត់ចែងឲ្យគេទៅនិមន្តព្រះសង្ឃពូកែនោះមក ។

នៅល្ងាចត្រជាក់ ឡានទាងថូក៏ត្រឡប់មកឈប់នៅមុខផ្ទះយាយនួនវិញ ស្ត្រីនេះឃើញហើយ ក៏មានវាចាទៅកាន់ជនម្នាក់ក្នុងបណ្តាភ្ញៀវទាំងឡាយ ដែលមកសួរដំណឹងត្រៀបត្រា ឲ្យចុះទៅអារាធនាភិក្ខុឡើងលើផ្ទះ ។ ព្រះសង្ឃរូបនេះមានវ័យចាស់គ្រាន់បើហើយ ដំណើរកោងច្រត់ទៅលើឈើមួយ ហើយមានសាច់ជ្រីវជ្រោកដណ្តប់ ដោយចីពរជ្រលក់ខ្ចីមខ្មុរ ។

លុះគេបាននិមន្តលោកឲ្យឡើងរួចហើយ លោកក៏មកគង់កន្លែងមួយដែលគេរៀបបំរុងជាមុន ។ ក្រោយដែលគេលើកទឹកតែ បារី ម្លូ ស្លាមកប្រគេនលោក លោកក៏មានថេរដីកា សួរដោយសំដីស្លូតៗមួយៗ :

- ញោមនិមន្តអាត្មាមកនេះ តើមានការដូចម្ដេចខ្លះ ?

យាយនួនគាត់ក៏ខិតចូលជិត ហើយនិយាយពិតលោកតាមដំណើរ ។ ភ្ញៀវម្នាក់ដែលនៅជិតខាង ក៏លើកថាំងមួយដាក់ទឹកពេញមកប្រគេនលោក ។ ក្នុងភាជន៍នេះមានផ្កាម្លិះក្រពុំៗអណ្ដែតសក្បុស ។ លោកយកធូបបីសរសៃមកផ្ដុំគ្នានឹងដុំក្រមួនមួយប៉ុនកូនដៃ ហើយយកទៅបិទភ្ជាប់នឹងមាត់ធុងទឹក ។ លោកអុជទានមួយឲ្យឆេះ ហើយយកទៅបង្កាត់ធូបបីសរសៃនោះឲ្យឆេះទៀត ទើបបិទទាននោះនៅក្បែរធូប ។ លោកលើកហត្ថប្រណម្យហើយសូត្រផ្លុំៗទឹកក្នុងថាំង ។មួយស្របក់ក្រោយមកលោកបែរយកទៀនអុជមកសូត្រកូរទឹកទៀត បង្កើតឲ្យមានជាខ្សែទឹកនាំពពួកផ្កាម្លិះ ហែលរសាត់តាមគ្នាមានវិស័យដូចជាកូនក្ងុកសម្បុរស ។

យូរៗ ម្ដង លោកបង្អោនប្រឆេះទៀនទៅក្នុងទឹកបណ្ដាលឲ្យកើតជាផ្សុះប្រែះៗ ! ហើយមានក្រមួនរលាយធ្លាក់ចុះទៅអណ្ដែតត្រា ។

នៅកំឡុងកន្លះម៉ោង ដែលព្រះសង្ឃនេះសូត្រមន្តកូរទឹកពពួកភ្ញៀវ និងអ្នកម្ចាស់ផ្ទះអង្គុយបត់ជើងធ្វើមុខស្ងួត ភ្នែកចាំងផ្ទៀងមើល ។ នៅពេលបង្ហើយលោកក៏ជ្រមុជទៀន ទៅក្នុងទឹកពន្លត់តែម្ដង ។ អ្នកដែលនៅចាំជួយមើលការ លុះឃើញដូច្នោះហើយក៏នាំគ្នាគ្រាហ៍នាងវិធារីអង្គុយនៅមាត់ជណ្ដើរ ។ ព្រះសង្ឃក៏លើកទឹកនោះ ទៅស្រោចលើខ្លួននាងដែលកំពុងគ្រុនយ៉ាងក្ដៅ នៅពេលព្រលប់ធំដែលធ្លាក់ត្រជាក់ ។ នាងវិធារីដែលគេបានដោះអាវចេញទុកឲ្យនៅខ្លួនទទេ ដើម្បីទទួលទឹកមន្តកាលបើត្រូវខ្យល់បក់មកតិចៗ ។ ហើយក៏កើតរងាញ័រញាក់ទទ្រើត តែនាងខំខាំធ្មេញសង្កត់ចិត្ត ។ ដល់លោកលើកទឹកចាក់ទៅលើថែមទៀត ខ្លួននាងក៏ញ័រចំប្រប់ដូចកូនសត្វ មានធ្មេញរណ្ដំគ្នាគួរឲ្យអាណិតពន់ពេក ។



យាយនួនឃើញដូច្នោះ ក៏នឹកស្រណោះស្ទើររលួយថ្លើមប្រមាត់ ។ គាត់ក៏ខំហាមាត់ទាំងអួលអាក់និយាយ :

- ខំអត់ទៅកូន ! លោកតាស្រោចឲ្យឯងជាហ្មង ។

មុនពេលដែល លោកនឹងនិមន្តទៅកាន់ទីសម្នាធិវិញ លោកមានសង្ឃដីកាផ្ដាំថាស្អែកលោកនឹងនិមន្តមកម្ដងទៀត លុះគ្រប់បីដងទើបឈប់ ។

នៅយប់នោះ នាងវិធារីក៏ចាប់គ្រុនយ៉ាងខ្លាំង ។ ក្នុងទ្រូងនាងក្ដៅដូចរងើកភ្លើង ។ អ្នកផងតែងតែដឹងថាជម្ងឺទ្រូងនេះ តាមនិយមវេជ្ជសាស្ត្រនៃបច្ចុប្បន្នកាល គេតែងតែហ៊ុមជណ្ដប់ឲ្យជិតមិនឲ្យត្រូវអាកាសត្រជាក់ ឬទឹកត្រជាក់សោះឡើយ ។ ឥឡូវនេះលោកដែលជាបព្វជិត មានសីលមានធម៌ បានមកស្រោចទឹកបណ្ដាល ឲ្យរោគនោះរឹតតែធ្ងន់ ជាងមុនទៅទៀត !

នាងវិធារីតាំងតែពីនាងចាប់ឈឺមក នាងឥតមាននិយាយស្ដីទេ ។ នាងនឹកឃើញថា ខ្លួននាងឈឺម្ដងនេះ ប្រហែលជាមិនជាទេមើលទៅ ។ ល្ហើយរស់ជាមនុស្សធ្វើអ្វីផង បើមុខជាមិនបានជួបគូសង្សារ មុខជាមិនសប្បាយ មុខតែរងទឹកភ្នែកដដែល ។ ឱបង ប៊ុន-ធឿន អើយ ! បងកុំប្រកាន់ទោសដល់អូនឡើយ ដោយអូនមិនបានមករួមជីវិតដូចពាក្យសន្យា ។ ឱគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដ៏ប្រសើរថ្លៃថ្លា ខ្ញុំសូមប្រាថ្នាថាកើតជាតិកាលណា កុំឲ្យមានព្រួយនិងព្រាត់គូកំសត់ដូច្នេះឡើយ ។

នៅយប់នោះ មានអ្នកជិតខាងជាច្រើននាក់ដែលធ្លាប់ស្រឡាញ់រាប់អាននាងវិធារី បានមកនៅជួយកំដរកុះករ ។ តែឥតមានជនណាមួយធ្មេចភ្នែកបានឡើយ ព្រោះនាងវិធារីចេះតែភ្ញាក់ខាកស្ដោះមកធ្លាក់ឈាមមិនស្រាកស្រាន្ត ។

លុះដល់ព្រហាម ទើបអ្នកជម្ងឺបានស្រយាលសម្ងំទទួលដំណេកបាន ។ យាយនួនគាត់ឆ្លៀតយកឱកាសនេះរត់ទៅ និមន្តលោកគ្រូអានមើលជតាកូនគាត់ ។ ព្រះសង្ឃរូបនេះ កាលបើបានពិនិត្យក្រាំងគម្ពីរ និងវាយលេខគន់គូរសព្វគ្រប់ហើយ ក៏មានសង្ឃដីកា :

- ញោម កូនញោមមានគ្រោះធ្ងន់ ។ លេខចង្អុលត្រង់ព្រះរាមត្រូវសរឥន្ទជិត ។ បើដូច្នេះ ចាំអាត្មាទៅសូត្របណ្តោះគ្រោះឲ្យ ។ ញោមកុំព្រួយ រោគនេះធ្ងន់មែនពិត តែគង់រកគ្រូមើលជា ។

នៅពេលថ្ងៃរសៀល គេឮសូរព្រះឱស្ឋលោកគ្រូអានសូត្រធម៌រអ៊ូ ហើយបាចទឹកមន្តដូចជាគ្រាប់ភ្លៀងធ្លាក់មកលើរាងកាយនាងវិធាវី ដែលរងាញ័រចំប្រប់នៅក្រោមភួយ

លុះសូត្រចប់ លោកគ្រូអានក៏បង្គាប់ឲ្យគេលើកអ្នកឈឺអង្គុយសណ្តូកជើងហើយលោកទំពាស្លាគ្រៀមគ្រួបៗ មានសូត្រគាថាបណ្តើរផង បុំន្មាននាទីក្រោយមក លោកក៏ព្រួស កញ្ចាក់ស្លាម្លូព្រមទាំងទឹកមាត់ក្រហមទៅលើនាងវិធាវីឮសូរផែតៗ ។

បន្ទាប់ពីពេលដែលលោកគ្រូអាននិមន្តផុតទៅ នាងថូក៏ឡើងមកដល់ភ្លាមមាននាំទាំងស្រីម្នាក់មកផង ។ ភ្ញៀវថ្មីនេះមានភ្នែកបាយម្ខាងស្រលៀងម្ខាង អុតស៊ីសុសមុខសក់ក្រញាញ់កន្ទ្រើងស្លៀកចងក្បិន និងពានាក្រមាមួយជាប់ក្អែលឡើងពភ្លក់ដែល អ្នកផងមិនអាចថា ពណ៌អ្វីបានឡើយ ។

លុះបានសួរដំណឹងសព្វគ្រប់ ពីអ្នកឈឺរួចហើយ នាងថូក៏និយាយទៀត :

- ថ្ងៃនេះខ្ញុំមិនបានឲ្យឡានទៅនិមន្តលោក ភ្នំសំពៅទៀតទេ ព្រោះខ្ញុំនឹកពិភាល់ថាមានទាស់ខុស នឹងខ្មោចបិសាចណាក៏មិនដឹង បានជាស្រោចទឹកម្តងហើយនៅមិនឃើញគ្រាន់សោះ ។ ហេតុនេះ បានជាខ្ញុំនាំម៉ែអេងដែលល្បីខាងចេះបូលឆុត ឲ្យគាត់មកបូលលមើល ក្រែងលោជាធ្វើទៅបានសមប្រកប ។

យាយនួនតប :

- គាប់ចិត្តថូពេក ជួយឈឺឆ្អាលយ៉ាងនេះ ខ្ញុំអរគុណណាស់ ។ បើយ៉ាងនេះហើយអញ្ជើញគាត់មើលទៅ ។

ម៉ែអេង ឮដូច្នោះហើយក៏បង្គាប់ឲ្យយកប្រណាក១ អង្ករមួយគ្រាប់ និងអំបោះមួយសរសៃ ។ គាត់យកអំបោះចងទងប្រណាកមួយខាង លៃឲ្យល្មមតែវត្ថុនោះនៅស្មើត្រង់ បើប្រសិនណាគេចាប់អំបោះយួរឡើង ។លុះលៃបានស្រួលហើយទើបម៉ែអេងយក



គ្រាប់អង្ករ មកដាក់បន្ទុំលើក្បាលប្រណាកដែលកាន់បន្តោងលើខ្លួនអ្នកឈឺ ។ ក្នុងគ្រានោះគេមានអុជទៀនធូបបិទនឹងមាត់ពានមួយ ។ ម៉ែអេងក៏និយាយឧទ្ទិសឡើងថា : ឱអ្នកមេបារូបណាមួយហើយ ដែលមានសេចក្តីក្តៅក្រហាយខឹងសំបា ហើយចូលមកធ្វើរូបអ្នកនេះ នាងនេះឲ្យឈឺនោះ សូមមេត្តាប្រាប់ឈ្មោះមកដើម្បីឲ្យនាងប្អូនគេរៀបសែនព្រេនជូន ។ ថាហើយម៉ែអេងក៏អង្គុយនឹងថ្កល់ ភ្នែកស្រលៀងខំ ស្រងៀវមើលប្រណាក ។ ទើបគាត់សួរ "អ្នកតាដំបងដែកហ៎ ? អ្នកតាក្បាលក្រហម ?" ប្រណាកនៅស្ងៀមឥតកំរើក ម៉ែអេងក៏ចេះតែរាប់ឈ្មោះអ្នកតា អ្នកដូច សួរយ៉ាងនេះតទៅទៀតទាល់តែដល់ឈ្មោះនាងកន្ទោងខៀវ ប្រណាកនោះក៏តាំងកន្ត្រោងមុជងើបៗ ទំលាក់គ្រាប់អង្ករទៅលើទ្រូងនាងវិធាវី ។ តាមយោបល់អ្នកតែមិនជឿខ្មោចបិសាចនោះ គេថាគឺម៉ែអេងនេះបន្លំកន្ត្រាក់សរសៃអំបោះបានជាប្រណាកចេះកំរើកយ៉ាងនេះ ។ តែតាមយោបល់អ្នកដែលជឿវិញ គេហ៊ានប្រាកដថា គឺជាអ្នកដូនកន្ទោងខៀវនេះឯង ដែលមកបៀតបៀនបុត្រីយាយនួន ។

បានស្គាល់ឈ្មោះបិសាច ដែលធ្វើកលដូច្នេះហើយ ម៉ែអេងក៏បង្គាប់ឲ្យធ្វើពែច្រមុះជ្រូកសែន ។ ហើយយកទៅចោលនៅទិសឦសាន ។ នៅពេលល្ងាចនោះ គេឃើញមនុស្សប្រមឹក បួន ប្រាំនាក់ កាន់ស្គរជាសដោយស្បែកពស់ថ្លាន់និងក្រពើ ចូលមកលេងភ្លេងញ៉ែៗ ហើយច្រៀងបន្ទរផង ឮរំពងដូចហ៊ឹងយំ នៅពេលភ្លេងដំបូង ។ ឯម៉ែអេងវិញគាត់ពាក់អាវបំពង់ព្រៃក្រហម អង្គុយសម្លឹងតោក ដងខ្លួនគាត់ញាក់ពព្រើត ។ មួយសន្ទុះក្រោយមក គាត់ចាក់ស្រាសជីកមួយពែង ហើយធ្វើសំឡេងស្អកៗថា ចង់ស៊ីកន្ទន់បាក់ក ។ អ្នកដែលនៅជិតខាងទីនោះ ក៏ស្ទុះយកចេកមួយស្និតមកឲ្យ ។ តួមេមត់ពមចេកអស់ពីរ បី ហើយក៏ចាប់យកតោកគ្រវីគ្រវាត់ហើយក្រោករាំចាក់ក្បាច់ ធ្វើដៃជើងជង្គ្រឹងជង្គ្រាងមួយសន្ទុះក៏អង្គុយស្ងៀម ឯភ្លេងនិងចំរៀងក៏ឈប់នៅស្ងៀមដែរ ។

ចំណែកម៉ែផៃវិញ កាលបើគាត់ឃើញនាងតូចរបស់គាត់ឈឺចាប់ខ្លាំង យ៉ាងនេះហើយ គាត់ក៏ភ័យស្លុតចិត្តស្ទើររកព្រលឹងគ្មាន ។ នៅល្ងាចដែលគេលេងមេមត់ដើម្បីសូមឲ្យបិសាច អភ័យទោសនោះ គាត់បានរ៉ាប់រងធានាខ្លួននឹងមកសុំឲ្យបិសាចស្រណោះ

ដល់នាងតូច ។ លុះដល់ ឃើញតួមេមត់គេឈប់ស្ងៀមដូច្នោះហើយ គាត់ក៏លើកដៃសំពះហើយថា :

- ឱលោកម្ចាស់អើយ ខ្ញុំសូមទោសចុះ គ្នានៅក្មេងណាស់ ? កុំចាប់ទោសពៃរ៍ធ្វើអី ឲ្យគ្នាបានជាស្រាកស្រាន្តទៅ ។

មេមត់ឆ្លើយតប :

ក្មេងនេះព្រហើនណាស់ ធ្វើឲ្យយើងខឹងណាស់ ! យើងខឹងណាស់ !តែឥឡូវនេះ គេបានឲ្យយើងសប្បាយរួចហើយ មិនអីទេ យើងព្រមឲ្យជាបាន ...

ឯនាងវិធាវីដែលទុក្ខអួលក្តៅនោះ កាលបើឮភ្លេងអារក្សយ៉ាងនេះនាងរឹតតែក្តាញ់ក្នុងចិត្ត តែមិនចេញស្តី ព្រោះនាងដឹងខ្លួនថា រោគព្យាធិនេះ កើតឡើងដោយទុក្ខព្រួយរបស់នាងប៉ុណ្ណោះ ។ ឱបើប្រសិនណាជាយាយនួនគាត់ភ្ញាក់ដឹងខ្លួន ហើយផ្តាច់នាងពីឈ្មោះ ណៃ ស៊ិតសំអប់ចេញ ហើយលើកនាងដាក់ទុកឲ្យទៅ ប៊ុន-ធឿន គូព្រេងវិញ ឱម្ល៉េះហើយសមនាងមានកំលាំងទទួល ឱសថ ទទួលម្ហូបអាហារដោយរីករាយ ហើយនឹងបានសះស្បើយជម្ងឺដោយរហ័សពុំខាន ។ តែនាងនៅតែមិនហ៊ានចេញស្តីសោះ ដោយខ្លាចទាស់ចិត្តម្តាយ ។ ម្ល៉ោះហើយ ខ្លួននាងចេះតែស្រពោនរញូមទៅៗ រាល់ថ្ងៃ ។

អ្នកដែលថែរក្សាជម្ងឺ រឹតតែខំបំពោកថ្នាំ មិនថាថ្នាំអ្វីជា ថ្នាំអ្វីទេ ចិនក៏មាន យួនក៏មាន ខ្មែរក៏មាន បារាំងក៏មាន ... អស់ពីភ្លុកដំរី ប្រមាត់ខ្លាឃ្មុំ អស់ពីឫសឈើ ដល់ថ្នាំធាបថ្នាំគុលិកា ថ្នាំចាក់ ថ្នាំដោតសព្វគ្រប់អស់ហើយ ។

ពាក្យសន្យាលោកគ្រូអាននិងមេមត់ ព្រមទាំងរឹទ្ធានុភាព នៃមន្តអាគមលោក ភ្ញុំសំពៅ ក៏មិនឃើញជាបានផលប្រយោជន៍ឯណា ។ នាងវិធាវី ក៏នៅតែស្គកស្គាំង តែនាងនៅវិញ្ញាណចាំជានិច្ច ។ ល្ហើយធ្វើម្តេចកម្មក្រាស់របស់ខ្លួន ... ។





## ១១

និងថ្លែងពីប៊ុន-ធឿន ដែលនៅរៀន ឯវិទ្យាល័យក្រុងភ្នំពេញ ។ លុះចូលមកក្នុងខែចេត្រសាលាគេបិទទ្វារ ដើម្បីឲ្យកូនសិស្សនិងគ្រូទាំងឡាយបានឈប់សំរាកក្នុងរដូវក្តៅមួយខែ ប៊ុន-ធឿន ក៏បានជិះរថភ្លើង មកបាត់ដំបងជាមួយពួកម៉ាក ។ ដល់ក្រុងនេះហើយ ក៏ឡើងជិះរ៉ឺម៉កដំរង់ទៅកំពង់ព្រះភ្លាម ព្រោះការឃើញទីតំបន់នេះ នាំឲ្យទុក្ខទាំងប៉ុន្មានដែលក្រាបនៅក្នុងបេះដូងរៀងរាបមក កញ្ជ្រោងរោលដើមទ្រូង ហើយធ្វើអោយគិតទៅគួសង្សារជាពន់ពេក ។ ណ្ហើយស៊ូផ្តាច់ចិត្តកុំឲ្យគ្នាសៅហ្មងដោយសារខ្លួនឯង ឲ្យគ្នាបានសុខសាន្តទៅចុះ ។

ប៊ុន-ធឿន ចិតបានពីរបីថ្ងៃជាមួយឪពុកម្តាយ ក៏មានដំណឹងចចាមអារ៉ាមថា បុត្រីយាយនួនជិតនឹងរៀបការហើយ ថាខាងប្រុសគេបានជញ្ជូនទាំងប្រដាប់ប្រដាបំរុងទុកសំរាប់ធ្វើរោងជាស្រេច ។ ប៊ុន-ធឿន នឹកស្រណោះខ្លួនពេកទប់មិនបានក៏ចូលទៅក្នុងបន្ទប់ ហើយដេកទទូរផ្ទួយយំខ្សឹកខ្សួលតែម្នាក់ឯង ។

នៅពេលល្ងាចថ្ងៃនោះ តាសូដែលជាមនុស្សបំរើនៃចិក ប៊ុន -ថនបានចូលមកសុំទៅរកត្រឹងព្រៃនាម ដំណើរនេះត្រូវដេកផ្លូវកន្លះខែទើបវិលវិញ ។ ប៊ុន-ធឿន ដែលមានប្រាថ្នាចង់ចូលទៅព្រៃសមសាន ព្រោះយល់ថា ធម្មជាតិជាកម្លាំង ជាវត្ថុព្រៃផ្សៃអាចញ៉ាំងសេចក្តីរំលាយទុក្ខសោកឲ្យបានជានិច្ច ក៏ចូលមកសុំឪពុកម្តាយទៅជាមួយតាសូផង ។

គ្រានោះចិក ប៊ុន-ថន ដែលមើលធ្លុះក្នុងចិត្តកូនក៏ព្រមបើកឲ្យទៅភ្លាម ។ចំណែកនាង សោភ័ណជាប្អូនវិញ ដែលមានបារម្ភផ្សេងៗតាមធម្មតាស្ត្រីនោះក៏និយាយអង្វរបងកុំឲ្យទៅរនាមធ្វើអ្វី ព្រោះខ្លាចមានឈឺថ្កាត់ក៏មិនគាប់ មានសត្វសាហាវបៀតបៀនក៏មិនគាប់ ។ ប៊ុន-ធឿន ឮហើយ ក៏តបទៅវិញ :

- ប្អូនឯងកុំព្រួយឲ្យសោះ ព្រោះនៅក្នុងរនាមគ្មានខ្លា គ្មានរមាសទេ មានតែជ្រឹប៉ុណ្ណោះ ។ ឯជ្រឹនេះ បងមិនខ្លាចទេ បងចេះឡើងដើមឈើស្ទាត់ហើយ ។



យប់នោះ វេលាមាន់រងាវមួយដង តាសូគាត់រៀបចំរទេះ ឯនាងសោភ័ណ នាងដណ្តាំបាយដុតត្រីងៀត និងរៀបអង្ករត្រីសាច់ទុកឲ្យអ្នកដំណើរ ។ ប៊ុន-ធឿន ភ្ញាក់បើកទ្វារចេញមកក្រៅ ហើយសំឡឹងមើលទៅលើមេឃឃើញផ្កាយប្រុះថែមទាំងមានខ្យល់រហៀកៗ ធ្វើឲ្យអ្នកដែលក្រៀមក្រំមានកម្លាំងព្រើត ។ បន្តិចក្រោយមកគេក៏ឮមាត់តាសូស្រែកហ៊ុយៗ បង្ខំដេញគោឲ្យដើរលឿនទៅមុខ ហើយឮសូររទេះយំញ៉ែៗ ក្នុងផ្ទៃស្ងាត់នៃរាត្រី ។

កាលបើផុតភូមិ ចូលដល់វាលស្រែកាលណា រទេះតាសូ និង ប៊ុន -ធឿន ក៏ទៅជួបនឹងរទេះអ្នកស្រុកឯទៀត ចំនួនម្ភៃប្លាយ ។

នៅរដូវប្រាំង ដែលជាពេលទំនេរពីការច្រូតកាត់ អ្នកស្រុកភូមិកំពង់ព្រះ តែងនាំគ្នាទៅរកស៊ីក្នុងរនាម ខ្លះទៅរកកាប់ដើមរទាំងជីកយកមកទុកជាឧស ខ្លះស្វែងរកទឹកឃ្មុំ និងក្រមួន ខ្លះទៀតរកត្រីតាមបឹងបួ ។

ពួកអ្នក "ដើររនាម" តែងនាំគ្នាចេញរទេះពីយប់ព្រោះចង់ជៀសមិនឲ្យសត្វពាហនៈទាំងឡាយ ត្រូវកំដៅថ្ងៃសោះឡើយ ។ អ្នកស្រុកទាំងនោះមានចិត្តស្រណោះអាណិតគោ ក្របីគេជាទីបំផុត មិនចង់ឲ្យវានឿយហត់ដោយឥតផលទេ ។

ហ៊ុយ ! ហ៊ុយ ! តាសូគាត់ដេញគោឲ្យដើរលឿន ។ រទេះបុរសនេះបរទៅមុខគេបង្អស់ ព្រោះអ្នកដំណើរទាំងឡាយយល់ថា គាត់ចាស់ជាងគេនេះម្យ៉ាង ហើយម្យ៉ាងទៀតព្រោះគេនឹកអាណិត ប៊ុន-ធឿន មិនចង់ឲ្យកំលោះនេះមានរំខាននឹងធូលីហុយទៅលើសោះឡើយ ។ អ្នកស្រុកទាំងនោះរាប់អានស្រឡាញ់ ប៊ុន-ធឿនណាស់ ដោយគេយល់ថា ជាក្មេងចេះដឹងផង គ្រួសារប៊ុន-ធឿន សុទ្ធតែជាមនុស្សមានធម៌សប្បុរសទាំងអស់ផង មិនដែលរកស៊ីអារក ដូចគេឯទៀតទេ ។

រវាងមួយម៉ោង ក្រោយដែលចេញពីភូមិផុតមក ក្បួនរទេះក៏បរឆ្លងអូរតាត្រៃដែលរីងខះទឹកអស់ នៅតែដីបែកក្រហែង ។ លុះផុតព្រៃដងអូរនេះចូលទៅក្នុងវាលដក់ពាយហើយ ប៊ុន-ធឿន ដែលអង្គុយសញ្ជឹងសញ្ជប់មិនចេញស្តីថាអ្វី ក៏ងើបមុខ

មើលទៅទិសខាងកើត ហើយភ្ញាក់ខ្លួនព្រើត... នៅឆ្ងាយចំពីមុខមានភ្លើងប្រទីបឆេះ
ព្រោងព្រាត ។ ភ្លើងនោះរៀបរយល្អមើលណាស់ ខ្លះតំរៀបជាជួរៗ វែងៗ ដូចអគ្គិសនី
ដែលបំភ្លឺថ្នល់ទាំងពួងនៃទីក្រុង ខ្លះទៀតទំនៅទាប ខ្ពស់មានលក្ខណៈ ដូចជាចង្កៀង
ដែលបំភ្លឺគេហដ្ឋាន ឬទីលំនៅនានាក្នុងក្រុងនោះ ។ ពន្លឺដែលនៅរាយបណ្តោយ
ប្រមាណពីរគីឡូនេះ មានលំអយ៉ាងត្រកាល ដោយមានយប់ខ្មៅងងឹតរុំស្រោបជុំវិញ
ហើយស្ងួយបញ្ចេញឡើង ។ ប៊ុន-ធឿន ដែលមិនធ្លាប់ចូលរនាមនឹងគេ ក៏នឹកក្នុងចិត្តថា
ប្រហែលជាទីក្រុង ណាមួយប្រតិស្ឋកើតឡើងដោយទេពនិម្មិតក៏មិនដឹង ។ ឱកន្លែងនេះ
ទីនេះសមជាប្រាសាទសំរាប់ទទួលស្រ្តីណា នារីណាដែលមានរូបល្អឯក ដែលមានសាច់
ទន់ភ្លន់ ហើយដែលមានមុខញញឹមស្រស់ប្រិមប្រិយ ! ឱកន្លែងត្រង់នោះមួយទៀតសម
ជាគេហដ្ឋានរបស់សេដ្ឋីណាមួយហើយ ព្រោះផ្ទះនោះមានអុជភ្លើងដេរដាសជុំវិញ ។
ឱអូនវិធាវីអើយ បើប្រសិនជាយើងបានជួបរួបរួមវាសនាគ្នា ម្ល៉េះសមយើងនឹងជ្រើស
រើសមកសំចតនៅក្នុងទីក្រុងនេះ ប្រកបដោយសុខក្សេមក្សាន្ត ។ ឥឡូវនេះ មិនប៉ុន្មាន
ថ្ងៃទៀតទេ មុខជានាងទៅនៅជាមួយចៅណែសិតហើយ ! ម្ល៉េះសមអូនរងទុក្ខវេទនា
ព្រោះបងស្គាល់ចិត្តអូនជាក់ ថានាងមិនដាច់អាល័យពីបងឡើយ ។ ខ្ញុំសូមបួងសួងអស់
អារក្សទេវតាដែលឋិតនៅឋាននេះឲ្យជួយ តំរង់ចិត្តអូនវិធាវីឲ្យនាងភ្លេចខ្ញុំចេញចុះ
ដើម្បីឲ្យនាងនិត្យនៅជាមួយប្តីនាងជាសុខុម ។ នាងមានចិត្តស្លូតត្រង់ដឹងខុសត្រូវណាស់
គួរតែរស់នៅនិងព្រួយបារម្ភ ដើម្បីជាត្រួយជាផ្កាសំរាប់លំអមនុស្សជាតិ ។

ប៊ុន-ធឿន កំពុងតែរវើរវាយក្នុងសន្តានចិត្តដូច្នេះ ស្រាប់តែឃើញព្រៃក្រហម
រើៗ នៅចំពីខាងកើត ។ ខណៈនោះកងរទេះបានបរផុតវាលហើយចូលក្នុងព្រៃរនាម
ទើប ប៊ុន-ធឿនអាចកាត់ប្រស្នានៃរឿងទីក្រុងដែលភ្លឺសន្ធោក្នុងរាត្រីបាន ។ នៅពេលថ្ងៃ
ដែលកំពុងក្តៅអស្ចារ្យ ភ្លើងដែលបណ្តាលឡើងពីអ្នកប្រហែលចោលកន្ទុយបារី ឬអង្កត់
ឧសទៅលើស្មៅស្ងួត ឬមួយបណ្តាលឡើងដោយស្នាដៃអ្នកដុតស្មៅ រកអណ្តើកក៏ឈ្មួល
ឆេះ រាលដល់វល្លិ៍ទាំងពួងដែលដុះព័ទ្ធដើមឈើធំៗ ។ លុះភ្លើងស្មៅនោះស្ងប់រំងាប់ទៅ



ក៏មានភ្លើងកាត់ខ្លះនៅចុង ខ្លះនៅប្រគាប ខ្លះនៅគល់នៃរុក្ខជាតិ ។ នៅពេលយប់ត្រូវ
មានខ្យល់បក់បន្តិចៗ ផង ភ្លើងនោះក៏ឆេះមានអណ្តាតឡើង ។ បើគេមើលពីចំងាយទៅ
ឃើញហាក់ដូចជាពន្លឺចង្កៀងទីក្រុងសុទ្ធវិស័យ ព្រោះប្រវែងមុខភ្លើងធំទូលាយណាស់ ។
ហេតុដែលនាំឲ្យព្រឹក្សាទាំងឡាយជាចំណីភ្លើង យ៉ាងងាយទាំងម្ល៉េះ គឺមកតែពីស្មសាន
នេះមានច្រើន តែដើមរទាំងនិងត្នូរដែលអ្នកផងតែងដឹងថាជាឈើឧសយ៉ាងប្រសើរ ។

ប៊ុន-ធឿន គន់មើលព្រឹក្សា ដែលមានភ្លើងឆេះរូងដល់ខ្លឹម ដល់បណ្តូលហើយ
យកមកធៀបប្រដូចនឹងខ្លួន ដែលមានភ្លើងទុក្ខឆេះរោលរាលពេញទាំងទ្រូង ។ ឱ ! ឈើ
អើយមានខ្លះភ្លើងឆេះផ្តាច់ត្រឹមគល់ ខ្លះត្រឹមពាក់កណ្តាលដើម ខ្លះទៀតគ្រាន់តែឆេះ
រោលៗចុង ។ នៅលើពសុធានៃតំបន់នោះ គេឃើញតែដង្កត់ខ្មៅ ឃើញតែរងើកក្រហម
រន្ទាល ឃើញតែផេះសង្អោង ! ឯជីវិតនានាដូចជាចាកចោលទីកន្លែងនេះអស់ ។ គ្មាន
សត្វហើរ គ្មានសត្វយំ ស្ងាត់ស្ងួន្យ ជ្រងំ ! យូរៗ ម្តង គេឮសូរមែកឈើដែលភ្លើងកាត់
ផ្តាច់នោះធ្លាក់មកដី ឮប្រាវ ។

នៅពេលថ្ងៃជិតត្រង់ កងរទេះនេះបានបរដល់តំបន់មួយ ហៅដង្កោតាងិល ដែល
ជាទីខ្ពស់ ១ ទីករដូវវស្សាមិនដែលលិចទេ ។ បានជាអ្នកផងហៅថាទួលដង្កោតាងិល
ដូច្នេះ ព្រោះទួលនោះ មានដើមដង្កោមួយធំខ្មៅដូចធ្យូង តែកំបុតឥតចុងដោយរន្ទះ
បាញ់ផ្តាច់ជាយូរអង្វែងមកហើយ ។ រុក្ខជាតិនេះ មានស្លឹកនៅគ្រប់ប្រគាបប៉ុណ្ណោះ ។
នៅភ្ជាប់នឹងដើមដង្កោនេះ មានដើមអម្ពិលមួយធំណាស់ដែរ ដែលបែកមែកសាខា
ហាក់ដូចជា គ្របបាំងកុំឲ្យកូនខ្ទមតូចមួយដែលនៅអែបនឹងគល់មិនត្រូវកំដៅព្រះ
អាទិត្យឡើយ ។ នៅក្នុងខ្ទមមានបដិមាមួយធ្វើពីថ្មខ្មៅប្រផេះ ។ រូបនោះមានបបូរមាត់
ធ្លាក់សំបេះ ហើយមានផ្ទាំងជាតីរុំព័ទ្ធជាក្រមា ។ រូបចំលាក់នេះជារូបអ្នកតាដង្កោ
តាងិល ដែលមានរិទ្ធានុភាពខ្លាំងពូកែណាស់ ។ អ្នកដំណើររទេះ កាលបើបានដល់ទួល
នេះហើយ តោង ខ្ទឹមឃ្មាតកាច់មែកឈើ ច្រូចស្រា សែនបាយទឹក ចំណីចំណុក ដើម្បី
សូមលាភ សូមជ័យពីលោក អ្នកតា ។ រួចហើយ ទើបនាំគ្នាយកគោឲ្យផឹកទឹកបឹងមួយ

ដែលនៅប្របទីនោះ ហើយដែលមានទឹកថ្លាឈ្វេង ផឹកទៅត្រជាក់ដល់ថ្លើម ។ ក្នុងពោះបឹងនោះស្មៅវារីជាតិ ដូចជាស្មៅនិងព្រលិត ទាញចក្ខុវិញ្ញាណដោយលំអ ផ្ការីកភ្លឺរន្ទាល ឬសក្បុស ។ ភ្នែកជនដែលត្រេកត្រអាលនឹងទេសភាពទន់ត្រជាក់នេះ មិនងាយនឹងដកចេញពីទីនោះបានទេ ព្រោះមានហ្វូងក្រសារ រនាល មាន់ទឹក ដែលរកស៊ីដោយសន្តិភាពពេញទាំងបឹង បន្ថែមលំអ បន្ថែមមនោរម្យត្រួតទៅលើទីឋាននេះទៀត ។ សារាយនេះញញឹមស្រស់ ក្រោមរស្មីត្រចះនៃព្រះអាទិត្យ និងក្រោមផ្ទៃមេឃខៀវដែលឆ្លុះគំនូរទៅក្នុងទឹកថ្លាយង់ ។ អង្គុយក្រោមដើមចារមួយ ប៊ុន- ធឿន ក៏គយគន់រំពៃមើលពពួកបក្សីដែលដើរលបៗ ចាំឆ្មក់មច្ឆជាតិ ... ។

ពួកអ្នកដំណើរ កាលបើបានមុជទឹកជំរះខ្លួនរួចហើយ ក៏នាំគ្នាជំកង់អាស្រ័យបាយដែលអ្នកផ្ទះបានរៀបបំរុងមកឲ្យហើយ និយាយចំអន់គ្នាសើចខ្ញៀវខ្ញារ ។ ប៊ុន-ធឿន មុខនៅតែស្រពោនខំត្រដរលេបបាយបានពីរ បីម៉ាត់ប៉ុណ្ណោះ ។ រួចហើយ ក៏យកក្រមាមួយទៅក្រាលលើស្មៅដេកលេងក្រោមដើមចារ មើលសត្វ មើលមេឃ មើលដងព្រឹក្សព្រៃ ហើយសញ្ជឹងសញ្ជប់តែម្នាក់ឯង ។

នៅវេលាសូរិយាបន្ទាបគងមាត់ព្រៃ ពួករទេះអ្នកស្រុកនៃភូមិកំពង់ព្រះបានដល់ទៅកន្លែងមួយហៅវាលស្រីស្រណោះ ។ វាលស្រីស្រណោះ ! ឈ្មោះតំបន់នេះចំជាសម ចំជាត្រូវព្រោះជាទីកន្លែងមួយវាលស្មើ ហើយមានស្មៅចិញ្ចៀន និងស្លាបទាដុះជិតប្រកិតគ្នា ដូចជាកំរាលមួយដែលមានពណ៌បៃតងស្រស់ ហើយមានព្រៃដងអូរព័ទ្ធជុំវិញដូចជាកំពែង ។ ពេលល្ងាចវេលាថ្ងៃលិចហ្វូងបក្សីហើរមីរដេរដាសមកចាប់ទ្រនំ តាមដើមឈើដងព្រឹក្សព្រៃ ។

វាលស្រីស្រណោះ ! ធម្មជាតិនៅក្នុងទីនោះ មានសភាពដូចជាទឹកមុខនារីមួយដែលមានរូបល្អ ហើយដែលស្ងួតស្ងប់ក្រៀមក្រំ ដោយមានព្រួយក្នុងចិត្ត ។

វាលស្រីស្រណោះ ! ប៊ុន-ធឿនឮតែឈ្មោះវាលនេះឡើង ក៏កើតរំជួលញាប់ញ័រអស់អង្គកាយ ។ ឱ ! រិធាវីត្រួយជីវិតបងស្គាល់ចិត្តនាងជាក់ណាស់ មុខតែនាងមិន



ភ្លេចសេចក្តីស្នេហាដើមទេ ។ ឱ ! ម្ល៉េះសមនាងខំទ្រាំទ្រស្វាមីនាងដែលនាងគ្មានប្រតិព័ទ្ធដល់ប៉ុនសរសៃសក់ឡើយ ។

កាលបើបានដល់វាលស្រីស្រណោះហើយ ពួកអ្នករទេះក៏រហ័សដៃរហ័សជើង ខ្លះទៅរកឈើព្រៃមកធ្វើជាឧសទុកដុតឲ្យសន្ធោសន្ធៅក្នុងពេលយប់ ដើម្បីកុំឲ្យហ្វូងដំរីព្រៃមកបៀតបៀន ខ្លះក៏ស្លដណ្តាំ ខ្លះទៀតក៏កាន់ខ្សែវកាន់ពូថៅទៅឆ្ការព្រៃ យកទីកន្លែងដេកបណ្តោះអាសន្នទំរាំធ្វើជំរកបាន ។ ជនទាំងនេះធ្វើការបណ្តើរនិយាយគ្នាសើចលាន់រំពងបណ្តើរ ។

នៅក្នុងចំណោមមនុស្សទាំងនេះ មានជនម្នាក់អាយុហាសិបឆ្នាំថ្លាយមាឧក្រអាញដងខ្លួនធំដំបង សក់កាត់ខ្លីសម្បុររបាយមូសខ្លា ។ បុរសនេះឈ្មោះប្រាក់ជាអ្នកខ្លាំងពូកែចេះមន្តអាគមធ្វើគ្រូហ្មបាន ។ គាត់ស្គាល់ផ្លូវរនាមខ្ទេចគ្មានសល់ ។ ពួកក្រុមដែលដើរព្រៃជាមួយគាត់មិនដែលស្គាល់ថា ដូចម្តេចហៅថាវង្វេងផ្លូវសោះឡើយ ។ តាប្រាក់មានសតិប្រាជ្ញាវាងវៃចេះចាំរឿងរ៉ាវសាស្ត្រា ដែលមានក្នុងវត្តកំពង់ព្រះទាំងប៉ុន្មានយ៉ាងស្ទាត់ ។ ហេតុនេះហើយបានជាពួកដើរព្រៃតែងតាំងគាត់ជាដង្ហៅ គឺជានាយក ។ បើគាត់និយាយបង្គាប់ថាដូម្តេច គេតោងស្តាប់គាត់ ហើយធ្វើតាមគាត់ជានិច្ច ។

នៅយប់នៃថ្ងៃដែលទៅដល់ វាលស្រីស្រណោះនោះពួកអ្នកដើរព្រៃបានស្រុះស្រួលគ្នាអង្គុយជក់បារីស្លឹកចេក នៅជុំវិញតាប្រាក់ ហើយឲ្យគាត់និយាយរឿងសាស្ត្រាកំសាន្តលេង ។ តាប្រាក់ក៏ចាប់ផ្តើមរឿង ព្រះជិនវង្សឲ្យពួកគាត់ស្តាប់ ... ។

យប់នោះ នៅពេលដែលអ្នកដំណើរទាំងឡាយដេកលង់លក់ ស្រមុកគគ្រឹកគគ្រេងរៀងខ្លួន ខ្ញុំហ៊ានអះអាងថា មុខជាមានអ្នកខ្លះយល់សប្តិឃើញរូបនាងបទុមសុរិយា ដែលកើតពីក្នុងផ្កា ឬនាងសុវណ្ណរេខានិងអញ្ជ័នពីចិត្រដែលជាបុត្រីយក្ខ ហើយប្រហែលជាអ្នកទាំងនោះដែលខ្លួនដេកនៅផ្ទាល់ពសុធានឹកគួចស្នេហា មមើស្រវារកស្ត្រីល្អឯកទាំងនោះពុំខាន ។ "ជន្លេនស្រឡាញ់ផ្កាយ!"

ឱព្រះនាងក្សត្រីទាំងឡាយដែលប្រតិស្ឋកើតឡើង ដោយប្រាជ្ញាចិត្តកវីដែលមានរូបឆោមលោមពណ៌ល្អឥតថ្មីមបាន ដែលមាននាមក្រអូបឈ្ងុយដូចបុប្ផាជាតិ ក្មេងទំទើបថ្មី គេបោះបង់ចោលអស់ហើយ ! ប៉ុន្តែក្លិនពិដោរព្រះនាងនៅតែអណ្តែតចេញពីសាស្ត្រាស្លឹករឹតមក ប្រលោមចោមបំពេជាដរាប នូវព្រលឹងអ្នកស្រែដែលធ្វើការនឿយហត់ ។

ពួកអ្នកដើរព្រៃ កាលបើបានសង់ជំរំរួចស្រេចហើយ ក៏ចាត់បំបែកគ្នាជាបីកង ។ មួយកងអ្នកដើររក ឃ្មុំយកកូនក្រមួននិងទឹក ។ មួយពួកទៀតជាអ្នកស្វែងនេសាទត្រីតាមបឹងតាមត្រពាំង ។ ឯផ្នែកទីបីជាពួកអ្នកនៅចាំជំរំ ថែទាំសត្វពាហនៈ និងយកត្រីដែលចាប់បានមកធ្វើជាប្រហុក ជាងៀត ជាឆ្អើរ ។

ចំណែក ប៊ុន-ធឿនវិញ ដែលមកតាមគេប្រុងតែនឹងរំហើយចិត្តនោះ មិនមានចូលជាពួកកងណាឲ្យប្រាកដទេ ។ ជួនណា ប៊ុន-ធឿន លីអង្រុត លីសមទៅតាមពួកនេសាទ ។ បើប្រសិនជាគេប្រទះបឹងណាធំពេក ឬ ដែលមានទឹកនៅច្រើននៅឡើយគេក៏ប្រើអង្រុត ប្រើសមទៅលុកលុយចាប់យកត្រី ។តែបើប្រសិនជាបឹងមានទឹករីងនៅតិចល្មមវិញ គេកកាយដីលើកភ្លឺបែងបំបែកបឹងជាពីរ ។ បន្ទាប់មកគេយកស្នាចធ្វើអំពីឈើ ឬ ធ្វើអំពីប៉ោតប្រេងកាតបាចបញ្ជូនទឹកពីភាគម្ខាងទៅភាគម្ខាង ទាល់តែខះទើបគេចាប់ត្រីដាក់ត្រកតែម្តង ។ រួចហើយទើបគេបាចទឹកពីម្ខាងដែលមានទឹកបញ្ចូលមកម្ខាងវិញ ។

នៅវេលាដែលគេចាប់ត្រី គេនិយាយសើចហ៊ោកញ្ជៀវ ខ្លះច្រៀងប្របកៃ ខ្លះហួច ខ្លះទះដៃទ្រហឹងអឹងកង ។ នៅក្រោមម្លប់ឈើមួយដុះនៅប្របមាត់បឹង មានខ្លះទៅរកឧសមកបង្កាត់ភ្លើង ហើយតាំងរើសយកត្រីរស់ណាធំៗធាត់ៗ បិទដីឥដ្ឋហើយកប់ទៅក្នុងងើក យកត្រីអណ្តែងខ្នាតធំៗទៅត្បុតនឹងមែកឈើ ហើយអាំង ចោលក្លិនឈ្ងុយនាំឲ្យស្រាវទឹកមាត់គ្រប់ៗគ្នា ។ ឯទឹកជ្រលក់សោតក៏គេយកមកលាយចំរុះជាមួយគ្នាក្នុងចានមួយ ដោយថែមអម្ពិលពីរបីគ្រាប់ និងទឹកជាពីរ បីច្រូចប៉ុណ្ណោះ ។ គេឥតប្រើជីរប្រើឱ្មអ្វីសោះឡើយ ។ តែម្ហូបនេះមានឱជារសឆ្ងាញ់ណាស់ ដោយមកពីធ្វើការនឿយហត់ ប៊ុន - ធឿន ដែលខ្នះខ្នែងក្នុងការនេសាទនោះ ក៏តែងអាស្រ័យបានឆ្ងាញ់រាល់ពេលហើយមិនប៉ុន្មានថ្ងៃ ក៏មានទឹកមុខស្រស់បស់សម្បុរឡើងក្រហមក្រម៉ៅ ។



មានថ្ងៃមួយ ប៊ុន - ធឿន បានដើរចូលព្រៃធំជាមួយពួករកឃ្មុំ ។ ឱកាសនេះធ្វើអោយ ប៊ុន - ធឿន សង្កេតឃើញថា ពួកអ្នកដើរព្រៃដើរលឿន ហើយធន់មិនងាយអស់កំលាំងយ៉ាងអស្ចារ្យ ។ មួយទៀតព្រៃសោតសឹងមានសភាព ដូចៗគ្នា មិនគួរគេចំណាំបានមិនឲ្យវង្វេងសោះឡើយ ។ បើកាលណាគេប្រទះហ្វូងឃ្មុំយកផ្កាគេចាំមើលវា បើសិនជាវាត្រឡប់រួចហើយឃ្មុំហើរទាបៗ ត្រង់ទៅទីណាមួយ គេនឹងយល់ថាឃ្មុំនោះមានសំបុកនៅឆ្ងាយមិនងាយនឹងតាមទៅរកទេ ។

តែបើប្រសិនវាយកផ្ការួចហើយ វាហើរឡើងទៅលើត្រដែតវិញ គេត្រូវដើរទៅតាមវា មិនយូរប៉ុន្មានក៏គង់ប្រទះនឹងសម្បុកវាពុំខាន ។ កិរិយាចម្លែកនៃឃ្មុំនេះ តាប្រាក់គាត់បានពន្យល់ ប៊ុន - ធឿន ថាសត្វនេះចង់បញ្ឆោតមនុស្សយើង ។ វាហើរខ្ពស់ដើម្បីឲ្យគេជឿថាសំបុកវានៅឆ្ងាយ វាហើរទាបៗ ឲ្យគេជឿថាវានៅជិត ។ មនុស្សកំណាចបានអារកាត់ប្រស្នានេះបានយូរមកហើយ តែសត្វទាំងនោះនៅតែមិនទាន់ភ្ញាក់ខ្លួននៅឡើយ ។

នៅពេលដែលគេប្រទះនឹងសំបុកឃ្មុំនីមួយៗ គេប្រមូលមែកឈើងាប់ស្លឹកឈើស្ងួត ចងផ្តោបធ្វើជាគប់ ហើយដុតបង្ហុយឲ្យមេឃ្មុំផ្អើលហើយរត់ចោលអស់ ទើបគេឡើងដើមឈើ ទៅដណ្តើមយកកូន យកទឹក យកក្រមួនវាមក ។

មានថ្ងៃមួយ ពួកអ្នកដើរព្រៃ កំពុងតែដើរងើយរកមើលសំបុកឃ្មុំតាមមែកត្នួរដែលដុះស្រឡូនយ៉ាងខ្ពស់ៗ ស្រាប់តែឮសូរបាក់មែកឈើប្រាវៗ ហើយឮសំរែកកកិតៗផង ។ តាប្រាក់ដែលបានដើរមកជាប់ជាមួយនោះ ក៏ស្រែកថា :“ កនយើងឡើងឈើដំរីដេញហើយ !” ។ អ្នកផងខ្មីឃ្មាតរត់ប្រវាឡើងទៅបំពួនខ្លួនឯលើចុងរុក្ខជាតិអស់ទៅ ។ សល់តែ ប៊ុន - ធឿនដែលកំពុងរវល់កេះបាយក្តាំងជ្រលក់ទឹកឃ្មុំអាស្រ័យ ។ អ្នកដែលឡើងចុងឈើនាំគ្នាងាកមើលទៅឃើញដំរីស្តមួយធំស្ទើង ចេញពីដុបព្រៃហើយបោលតំរង់ស្លុងទៅចំប៊ុន - ធឿន ។ បុរសនេះភ័យស្លុតពេកក៏រត់យក ទាំងឆ្នាំងបាយ ទាំងចានដាក់ទឹកឃ្មុំទៅជាមួយផង ។ ដំរីរត់ជិតទាន់ហើយ ! ១០ម៉ែត្រទៀត ! ...

៧ម៉ែត្រទៀត ... ៥ម៉ែត្រទៀត ! ... អ្នកនៅចុងឈើទាំងប៉ុន្មាន ភ័យញ័ររន្ធត់អស់ព្រលឹង មិនដឹងគិតធ្វើដូចម្ដេចមកជួយអ្នកមានអាសន្នបាន ។ នៅតែ ៥ម៉ែត្រទៀត ! ដំរីដេញប្រកិតៗរកតែ ប៊ុន - ធឿន យកឱកាសឡើងដើមឈើណាមួយក៏មិនបាន ! មួយសន្ទុះក្រោយមក ដែលយូរហាក់ដូចមួយសតវត្ស គេឮមាត់តាប្រាក់ស្រែកថា : ចោលឆ្នាំង ចោលចានទៅ ! ប៊ុន-ធឿន ភ្ញាក់ខ្លួន ហើយក៏គ្រវែងវត្ថុទាំងពីរនេះភ្លាម ។ ឯដំរីក៏ស្ទុះទៅព្យាយាមបុកបែនចាននិងឆ្នាំង នាំឲ្យប៊ុន-ធឿន មានពេលរត់ដោះខ្លួនទៅឡើងដើមរទាំងមួយទាន់ ។

មានយប់មួយ នៅពេលរំលងអធ្រាត្រអ្នកដើរព្រៃកំពុងដេកលក់ស្រមុកយ៉ាងក្សេមក្សាន្ត ស្រាប់តែសូរកាំភ្លើងបាញ់បីដងព្រមទាំងមាត់មនុស្សចំនួន ប្រហែលម្ភៃនាក់ស្រែកនាក់ហោយកជ័យ ។ យប់នោះឯងព្រះចន្ទ្ររះភ្លឺស្រឡះ ។ តាប្រាក់ភ្ញាក់ឡើងដឹងថាមានចោរប្លន់ ក៏ប្រមូលពួកកងគាត់កាន់ខ្សែ កាន់ដាវ កាន់ពូថៅ ហើយរត់ចូលព្រៃអស់ ។ គាត់ប្រាមប្រាប់គ្នាគាត់ថា យើងមិនត្រូវតស៊ូ នឹងពួកចោរក្នុងទីវាលនេះទេ ព្រោះពួកវាមាន "គ្រឿងប្រយោល" ត្រូវតែបណ្ដោយឲ្យវាយករបស់ទ្រព្យសិនចុះ ។

បន្តិចក្រោយមកពួកចោរដ៏មានគ្នាប្រាំពីរនាក់ កាន់កាំភ្លើងដែលមានមាត់ត្រែចាំងភ្លែតៗ ដោយពន្លឺព្រះចន្ទ្រ ដើរចូលស្រមក ។ កាលបើមកដល់ជំរំហើយ ពួកមនុស្សឧត្បាតខ្លះ ស្ទុះទៅស្រាយយកគោ ខ្លះក្រសាវយកត្រីងៀត ត្រីឆ្អើរ ក្រមួននាំគ្នាវេចស្លាយអឺអឹង ។

លុះពួកខ្មាំងចេញផុតទៅ តាប្រាក់ផុសខ្លួនពីក្នុងដុបយកត្រចៀកផ្ទៀងស្ដាប់សូរជើងគោ និងជើងចោរហានេយ្យុំដែលអន់ថយបន្តិចម្ដងៗក្នុងរាត្រី ។

តាប្រាក់និយាយប្រាប់គ្នាគាត់ :

- ពួកអានេះ ដើរផ្លាក់ទៅលើរនាមស្ទឹងចាស់ហើយ មិនអីទេគ្នាយើង យើងនឹងនាំគ្នាទៅចាំស្ទាក់ផ្លូវវានៅច្រកព្រៃឯមុខនុ៎ះ ។



ថាហើយគាត់នាំគ្នាដើរតាមផ្លូវកាត់តូច ដំរង់ទៅព្រៃងងអូរមួយ ។ លុះដល់កន្លែងដែលផ្លូវជើងទៅប្រសព្វ និងផ្លូវរទេះទៅរនាមស្ទឹងចាស់ហើយ តាប្រាក់ក៏បំបែកគ្នាគាត់ជាពីរកង មួយកងឲ្យប្រុងចូលលុកដណ្ដើមយកគោ មួយកងទៀតសំរាប់ចូលវាយដណ្ដើមយកសំពាយ ។

ព្រៃងងអូរយប់ស្ងាត់ ។ ពួចជ្រឹតដែកយំច្រែតៗឮមាត់ទីទុយដែលរកចាប់ក្ដាមស្រែក ម្ដងៗ ។ ពួកតាប្រាក់បំពួនខ្លួនក្នុងដុបកូនឈើស្ងាត់ឈឹងសូន្យ ។ ព្រះពាយត្រជាក់រំភើយក្លិនផ្កាព្រាំនិងផ្កាស្រឡិតក្រអូបឈ្ងុល ។ ឯព្រះចន្ទ្រពេញវង់បូណ៌មីហោះថិញ្ចៀងហាក់ដូចជារត់លេងពួនជាមួយដុំពពក ។

ពួកតាប្រាក់ចាំឃ្លាំ ... ចាំប្រុង ... តាប្រាក់ច្រឡំផ្លូវទេដឹង ? ពួកចោរដើរផ្លូវផ្សេង ឬយ៉ាងម្ដេច ?

- ទេ តាប្រាក់មិនច្រឡំទេ ។ បើពុំនោះតើគេនឹងតាំងគាត់ជាដង្ហៅដើរព្រៃឯណាបាន !

តាប្រាក់មិនច្រឡំផ្លូវទេ ព្រោះឥឡូវគេចាប់ឮសូរជើងគោដើរដែលរឹតតែខ្លាំងឡើងៗគេឮមាត់មេចោរសើចហោរកញ្ជ្រៀវសប្បាយដោយយល់ឃើញថាពួកអ្នកដើររនាមនោះ សុទ្ធតែជាមនុស្សកំសាកញី ឮសូរកាំភ្លើងមិនទាន់បានអីផង ក៏នាំគ្នារត់ចូលព្រៃអស់ ។ មេចោរសើចសំរួលហាស់ ៗ !

សើចសប្បាយ ហាស់ ! ហាស់ ! ...ស្រាប់តែមានសំរែកមួយស្ទុះឡើងកនយើងបានការហើយ ! ហើយពួកតាប្រាក់ក៏ស្ទុះស្រោកចូលដេញតាមកាប់ចាក់ពួកសត្រូវ ។ មនុស្សយង់ឃ្នងនេះតក់ស្លុតស្មារតី មិនមានតស៊ូអ្វីដល់តូចមួយសោះគិតតែនាំគ្នាបោះគ្រឿងសស្ត្រាវុធ បង្វេចបង្វររត់យកតែព្រះអាយុរៀងខ្លួន ។

មួយសន្ទុះក្រោយមក ពួកចោររត់ខ្វាត់ខ្វាយបាត់អស់ ហើយគេឮសូរមាត់តាប្រាក់ មានជ័យសើចហ៊ោកញ្ជ្រៀវវិញ ។

ជ័យជំនះរបស់តាប្រាក់ បានមានឡើងដោយពេញលក្ខណៈ ។ របស់ទ្រព្យ និងសត្វពាហនៈដែលចោរប្លន់យកបានប៉ុន្មាន ក៏ដណ្ដើមយកបានវិញឥតខ្វះមួយ ថែមទាំងបានរបស់តាងផ្សេងៗ ដូចជា កាំភ្លើង កាំបិត ព្វថៅ ពិល ទៃគ្រូ យ័ន ។ ឯមេចោរ និងកូនចោរម្នាក់ដែលក្លាហានតស៊ូមិនរត់ ក៏ដួលដេកស្លាប់ចង្រ្កាង នៅលើផ្លូវរទេះមានរបួសត្រង់ថ្ងាស និងក្បាលជាទម្ងន់ ។

តាប្រាក់គាត់ឲ្យពួកគាត់ខ្លះនៅយាមសាកសពកុំឲ្យសត្វបៀតបៀន ឲ្យពីរនាក់នាំពត៌មានទៅប្ដឹងមេឃុំ ហើយនឹងឲ្យពួកខ្លះទៀតដេញគោ និងវែករបស់ព្រទ្យត្រឡប់មកជំរំវិញ ។





# ១២

ក្រោយដែលបានទទួលសំបុត្ររាយការណ៍ ពីមេឃុំកំពង់ព្រះ អធិប្បាយពីដំណើរចោរប្លន់អ្នកដើររនាម និងពីដំណើរអ្នកដើររនាមបានតស៊ូ ហើយកាប់ចោរពីរនាក់មក ក្រុមអយ្យិការអមសាលាដំបូងបាត់ដំបង បានកោះហៅអ្នកដែលបានដើរព្រៃក្នុងគ្រានោះទាំងប៉ុន្មាន ដើម្បីយកមកស៊ើបសួរជាពន្លឺ ។

នៅល្ងាចដែលបានឲ្យការ ចំពោះមុខលោកព្រះរាជអាជ្ញារួចហើយ ប៊ុន-ធឿន មានអផ្សុកក្នុងចិត្តពេក ក៏ជិះរ៉ឺម៉កឆ្លងស្ពាន់ដែកមកត្រើយខាងកើត ។ លុះមកដល់មុខវត្តកណ្ដាលបានឮសូរភ្លេងទាមមឹង និងឃើញទង់ក្រពើធ្វើពីទេសឯកដោតឲ្យយោលតាមខ្យល់ ប៊ុន-ធឿន ក៏កើតស្រយង់ចំឡែកក្នុងបេះដូង ។

នៅក្រុងបាត់ដំបង គេនិយមដំកល់សពនីមួយៗនៅលើគ្រឿងតាំងព្រមទាំងគ្រឿងសក្ការបូជា បាន ៣ថ្ងៃ ៥ថ្ងៃ ៧ថ្ងៃ តាមថ្នាក់ធនធាននៃគ្រួសារ ទើបគេរំលាយជាការស្រេច ។

ប៊ុន-ធឿន នឹកឆ្ងល់ ក៏ជញ្ជឹងតែក្នុងចិត្តថា : អ្នកណាស្លាប់ហ្ន៎ បានជាធ្វើឲ្យខ្ញុំថប់ព្រួយក្នុងទ្រូងដូច្នេះ ?

ដើម្បីជំរះអោយអស់ពិភាល់ ប៊ុន-ធឿន ក៏ដើរទាំងក្រៀមក្រំចូលទៅក្នុងទីអារាមតាមផ្លូវក្រាលឥដ្ឋក្រហម ដែលបោសស្អាតរលីង ឆ្ពោះត្រង់ទៅមេរុដែលមានទេសឯកទំលាក់រំសាយពីពិដានមកព័ទ្ធជុំវិញជាមរណសញ្ញា ។

នៅបាត់ដំបង គេរាប់អានតាំងរូបថតជនដែលទទួលមរណភាពមួយសន្លឹក ត្រង់មុខក្ការមឈូស ។

ប៊ុន- ធឿន កាលបើចូលដល់មេរុនោះហើយ ក៏ងើបសម្លឹងទៅមើលរូបថត ហើយស្រាប់តែញាប់ញ័រចំប្រប់ទឹកភ្នែកហូរសស្រាក់ ។ ជនកំលោះនេះខំត្រដរទៅផ្អែក



ទប់ខ្លួននឹងសសរមួយ មានទឹកមុខស្លឹតស្លាំង ។ បើប្រសិនណាជាមិនមានទឹកភ្នែកជោរជល់មកទេ ម្ល៉េះសមអ្នកផងគេនឹកស្មានថា មានខ្យល់គមកបៀតបៀនពុំខាន ។

នៅចំពីមុខក្ការមឈូស ដែលមានលំអដោយក្បាច់លាបទឹកមាសភ្លឺច្រាលឆ្អៅ រូបថតនាងវិធារីញញឹមប៉ប្រែសំឡឹងមកអ្នកមើលបុណ្យដែលដើរហូរហែ ។

ឱពុទ្ធោអើយ អូនវិធារី ! នាងមិនគួរមកក្ស័យជន្មអ្វីទាំងក្មេង ! ប៊ុន-ធឿន សំឡឹងមើលរូបថតហើយមើលទៀត មិនចេះអស់ចិត្ត នឹកពីភាល់ក្រែងលោច្រឡំមិនមែន ។

ឱអ្នកណាអើយ មកមានគំនិតយករូបថតនាងមកតាំងដូច្នេះ ! នាងញញឹម ... ញញឹមតែក្នុងរូបថតទេ តែកាលដែលនាងរស់នៅ នាងស្គាល់តែទឹកភ្នែក ! ។

ប៊ុន-ធឿនកំពុងតែឧឬកខ្យល់ ភ្លេចភ្លាំងស្មារតីយ៉ាងនេះ ស្រាប់តែមានដៃត្រជាក់ៗមួយមកអង្រួនចាប់ស្មា ។ កំលោះនេះភ្ញាក់ខ្លួន ហើយងាកមើលទៅស្គាល់ជាម៉ែផៃដែលមានសក់កោរថ្មីៗ ហើយស្លៀកពាក់សតាមធម្មតាអ្នកកាន់ទុក្ខ ក៏ញញឹមស្ងួតទៅរកស្ត្រីចាស់ ហើយនិយាយ :

ម៉ែផៃអើយ ខ្ញុំបែកទ្រូងស្លាប់ឥឡូវហ្នឹង

យាយផៃគាត់នៅស្ងៀមមួយសន្ទុះ ទើបឆ្លើយ :

- លោកក្មួយអញ្ជើញមកតាមខ្ញុំ ។ អ្នកនួនគាត់ទន្ទឹងផ្លូវលោកក្មួយជាយូរថ្ងៃហើយ ។

- ម៉ែផៃអើយ ខ្ញុំគ្មានការអ្វីទាក់ទងនឹងមីងនួនទៀតទេ

ជនទាំងពីរនេះដកដង្ហើមធំ ហើយនៅស្ងប់ស្ងៀមមួយស្របក់ទើបម៉ែផៃគាត់ថ្លែង :

- លោកក្មួយអញ្ជើញតាមខ្ញុំមក ព្រោះខ្ញុំឮគេថា នាងតូចបានសរសេរសំបុត្រមួយទុកជូនលោកក្មួយ ។

ឮហើយ ប៊ុន-ធឿន ក៏ដើរដូចមនុស្សមមើតាមម៉ែផៃឆ្ពោះទៅរោងចុងភៅ ។

បន្តិចក្រោយមក ប៊ុន-ធឿន ក៏បានដើរដល់ ហើយបានសង្កេតឃើញស្ត្រីម្នាក់ស្បែកទ្រុឌទ្រោម ថ្គាមខួង ភ្នែករូង ដេកវៀនជិតកញ្ជើអីវ៉ាន់ម្ហូបអាហារ ។ ម៉ែផៃក៏លូនចូលជិតស្ត្រីនោះ ហើយនិយាយសំដីយ៉ាងទន់ :

- អ្នក ! អ្នក ! ក្មួយប៊ុន-ធឿនមកហើយ ។

យាយនួនគាត់បើកភ្នែកដែលមានទឹកនេត្រាហូររហាមហើយសួរ :

- អ្នកណាហ្នំ ?

ចាំះអ្នក ក្មួយប៊ុន-ធឿន មកដល់ហើយ

ប៊ុន-ធឿន ដែលកាលពីដើមមានចិត្តគ្នាន់គ្នាញ់ នឹកស្អប់យាយនួនដោយបានពង្រាត់បំរាស់គូសង្សារ លុះមកឃើញស្ត្រីនេះ មានរូបស្គមស្លឹតស្លាំងដូច្នេះ សេចក្តីគុំកួនទាំងប៉ុន្មាន ក៏រសាយអស់មួយរំពេច ហើយសេចក្តីអាណិតអាសូរក៏បែរមកជ្រួតជ្រាបក្នុងដួងចិត្តថៅមាណពវិញ ។

យាយនួនគាត់ក្រោកអង្គុយហើយនិយាយខ្សាវៗ :

ប៊ុន-ធឿន ឯងចូលជិតមក ។

កំលោះក៏ប្រតិបត្តិតាមសំដីនេះដោយស្ងប់ស្ងៀម ។ មួយសន្ទុះទើបសំឡេងយាយនួននិយាយតទៅទៀត :

- ប៊ុន-ធឿន មីងបានជាខុសគំនិតទៅហើយ ... មីងមិនបាននឹកស្មានថាសេចក្តីស្នេហាមានកម្លាំងអ្វីម្លេះ ។ អាវី ថាតែឈ្មោះនេះហើយទឹកភ្នែកគាត់ហូរច្រោកៗ ។ គាត់ខំអត់មួយស្របក់ ទើបនិយាយទាំងអាក់អួលតទៅទៀតអាវីវាមិនភ្លេចក្មួយឯងទេ ។ មុននឹងដាច់ខ្យល់ទៅ វាបានប្រគល់សំបុត្រមួយច្បាប់និងចិញ្ចៀនមួយវង់ទុកឲ្យឯង ។



ថាហើយ យាយនួនក៏ស្រវាទាញកូនវ៉ាលីសស្បែកមួយមកបើក ហើយយកវត្ថុទាំងពីរមកប្រគល់ឲ្យ ប៊ុន-ធឿន ។ គឺចិញ្ចៀនត្បូងទទឹមមួយវង់ និងសំបុត្រដែលមានស្រោមបិទជិតមួយច្បាប់ ។

ប៊ុន-ធឿន ទទួលយករបស់ទាំងពីរនេះមកទុកក្នុងហោប៉ៅអាវហើយក៏លើកហត្ថសំពះលាភ្លាម :

- ទៅចុះក្មួយ ។

ប៊ុន-ធឿនដើរចេញមកដល់គ្រឿងតាំង ក៏ងាកមើលរូបថតសង្សារកំសត់ម្តងទៀត ។ ឱ ! អូនវិធាវីថ្លៃជីវិត មិនប៉ុន្មានថ្ងៃទៀតទេ គេនឹងរំលាយសព អូនទៅជាធូលីហើយ

- បងសំឡាញ់

នៅ " ពេលដែលបងអានសំបុត្រនេះ ខ្ញុំនឹងចូលមរណភាពបាត់រូបទៅហើយឱបងអើយ ... ខ្ញុំចាំទន្ទឹងមើលផ្លូវបងពីថ្ងៃមួយទៅថ្ងៃមួយ ។ មុននឹងស្លាប់ មិនបានអ្វីគ្រាន់តែជួបមុខបងមួយភ្លែតក៏សុខចិត្តដែរ ។ តែឥឡូវ យូរថ្ងៃណាស់ទៅហើយបាត់ដំណឹងបងសូន្យឈឹងតែម្តង ។ ឯរោគសោតក៏ធ្វើឲ្យខ្ញុំឈឺសព្វអស់អង្គកាយ មិនមានស្រយាលឡើយ ។ ហេតុនេះហើយ បានជាខ្ញុំស៊ូព្យាយាម ត្រដរសរសេរម្តងបន្តិចៗ តែងជាសំបុត្រនេះ ទុកជាសេចក្តីលារបស់ខ្ញុំ ។ បងអើយ អូនលាហើយ ! ធ្វើម្តេចជាតិនេះកម្មក្រាស់ឈ្នានីសមិនឲ្យខ្ញុំនិងបងបានជួបគ្នា ។ ខ្ញុំសូមចិត្តបងកុំឲ្យកើតទុក្ខនឹងខ្ញុំច្រើនហួសប្រមាណ ។

" ជំពូកមួយទៀត ។ ខ្ញុំសូមចិត្តបងកុំនឹកប្រកាន់ខឹងនឹងអ្នកម្តាយអូនខ្លាំងពេក ។ ធ្វើម្តេចគាត់ជាមនុស្សចាស់ គាត់តែងកាន់គំនិតចាស់ ។ គាត់មិនមែនចង់ធ្វើបាបយើងទេ គាត់គ្រាន់តែយល់ខុសប៉ុណ្ណឹងទេ ។

" បង បើបងស្រឡាញ់អូនដោយស្មោះត្រង់ ចូរបងធ្វើតាមបណ្តាំខ្ញុំ នេះកុំខាន ។ ចូរបងត្រឡប់ទៅកាន់វិទ្យាល័យវិញ ហើយខំរៀនសូត្រឲ្យបានចំណេះខ្ពង់ខ្ពស់ ។ រួច

ហើយបងសំឡឹងមើលនារីណាមួយ ដែលអាចនាំសេចក្តីក្សេមក្សាន្តជូនបងបាន សូមបងដណ្តឹងយកធ្វើជាភរិយាទៅ ។ ឯចិញ្ចៀនត្បូងទទឹមដែលជាវត្ថុមួយគាប់ចិត្តរបស់ខ្ញុំលើសលប់ជាងវត្ថុឯទៀត ខ្ញុំសូមឲ្យបងទុកដាក់ដៃជាទីរលឹកផង ខ្ញុំជូនយុវតីនោះតទៅ

"បងអើយកុំទុក្ខពេក ។ ធ្វើម្តេចវាសនារបស់មនុស្សតែងតែប្រកបដោយសេចក្តីមិនទៀង មិនឋិតថេរដូច្នេះ ។

" អូនសុំលាបងហើយបង "

នៅពេលយប់ស្ងាត់ ប៊ុន-ធឿន បានអុជចង្កៀងមើលសំបុត្រនាងវិធារីដោយមានទឹកនេត្រាហូររហែងមិនដាច់ ។

នៅខាងក្រៅផ្ទះ ខ្យល់បក់ឮហ៊ូ ៗ ហើយយូរៗ គេឮសូរសំឡេងរលកខ្មោចយំម្តងៗ ។

ចប់